## ការគាំទ្រសំណួរជាភាគនៅក្នុងក្រុមជំនុំ

«គ្រីស្ទបរិស័ទគឺត្រូវប្រឈមមមុខនឹងសំណួរដ៏ពិតប្រាកដ។ តើព្រះគម្ពីរប្រាប់ពីរចនាសម្ព័ន្ធ របៀបរបបក្នុងការថ្វាយបង្គំ ការរៀបចំព័ន្ធកិច្ច និងកំណត់អត្ថន័យនៃភាពជាអ្នកដឹកនាំតាមព្រះគម្ពីរយ៉ាងដូចម្តេច? ទាំងអស់នេះគឺគ្រាន់តែជាគំរូនៃសំណួរដែលបានឆ្លើយតបយ៉ាងច្បាស់លាស់ ដោយប្រុងប្រយ័ត្ន និងបានយ៉ាងល្អ និងជាភាគថ្មីដកស្រង់ចេញពីក្រុម 9Marks។ ខ្ញុំពិតជាអរព្រះគុណសម្រាប់ព័ន្ធកិច្ចមួយនេះ ព្រមទាំងសម្រាប់តទ្ធិពលដ៏ល្អដែលមិនគួរឲ្យជឿ និងពេញដោយក្តីសង្ឃឹមក្នុងក្រុមជំនុំដ៏ស្មោះត្រង់។ ខ្ញុំពិតជាលើកទឹកចិត្តឲ្យលោកអ្នកមើលដោយយកចិត្តទុកដាក់លើអត្ថបទជាភាគទាំងនេះ»។

> **លោក អរ. អាល់បើត ម៉ូល័រ ជេអរ.** នាយកសាលាព្រះគម្ពីរ បាទីស្ទភាគខាងត្បូង។

«សំណួរដ៏ស្មោះត្រង់គួរតែទទួលបានចម្លើយដែលពេញដោយការគិតយ៉ាងល្អិតល្អន់។ ប្រសិនបើលោកអ្នកមិនប្រាកដថា ត្រូវចាប់ផ្តើមពីកន្លែងណាក្នុងការឆ្លើយសំណួរទាំងនេះទេ សូមអនុញ្ញាតឲ្យអត្ថបទជាភាគទាំងនេះធ្វើជាក្តារជ្រមុជនាំលោកអ្នកទៅដល់បាតជម្រៅចុះ។ កូនសៀវភៅតូចៗទាំងនេះគឺចង្អុលបង្ហាញអំពីគំនិតយ៉ាងល្អតតខ្វោះ ហើយកាន់តែល្អក្នុងការអានជាមួយមិត្តភក្តិម្នាក់ ឬជាមួយមិត្តមួយរយនាក់ក៏ល្អដូចគ្នាដែរ»។

> **លោកស្រី ហ្គ្លរៀ ហ្វើមែន** អ្នកនិពន្ធសៀវភៅដែលមានចំណងជើងថា “Missional Motherhood” និង “The Pastor’s Wife”។

«ក្នុងនាមជាគ្រូគង្វាលម្នាក់ ខ្ញុំធ្លាប់បានគេសួរសំណួរជាច្រើន។ អ្នកមិនជឿបានដើរតម្រង់មករកខ្ញុំក្នុងការស្វែងរកឲ្យបានយល់អំពីដំណឹងល្អ អ្នកទើបតែជឿថ្មីៗមិនប្រាកដក្នុងការដើរនូវជំហ៊ានបន្ទាប់ និងអ្នកជឿដែលកំពុងមានភាពចាស់ទុំដែលចង់បានជំនួយក្នុងការឆ្លើយតបពីគ្រួសារគ្រីស្ទបរិស័ទ មិត្តភក្តិ អ្នកជិតខាង ឬមិត្តរួមការងារផងដែរ។ នៅក្នុងស្ថានភាពបែបនេះហើយដែលខ្ញុំប្រាថ្នាថា ខ្ញុំនឹងអាចមានសៀវភៅមួយដែលអាចពន្យល់យ៉ាងសង្ខេប ឆ្លើយសំណួររបស់ពួកគេ ហើយចង្អុលបង្ហាញដល់ពួកគេនូវទិសដៅសម្រាប់ការសិក្សាបន្ថែមទៀតផងដែរ។ សំណួរក្នុងក្រុមជំនុំគឺជាអត្ថបទជាភាគមួយដែលផ្តល់នូវចំណុចទាំងនោះ។ កូនសៀវភៅនីមួយៗបានដោះស្រាយសំណួរមួយដោយយោងតាមព្រះគម្ពីរ ពន្យល់សង្ខេប និងការអនុវត្តជាក់ស្តែងផងដែរ។ អត្ថបទជាភាគនេះទំនងជាអាចហៅបានថា «សំណួរសម្រាប់ក្រុមជំនុំ» ប៉ុន្តែ វាក៏អាចហៅបានថាជា «ចម្លើយសម្រាប់ក្រុមជំនុំ» ផងដែរ។ ខ្ញុំមានទំនោរក្នុងការយកកូនសៀវភៅទាំងនេះរាប់សិបក្បាល និងបានចែករាដល់អ្នកដទៃជាប្រចាំ។ លោកអ្នកក៏គួរធ្វើដូចគ្នាដែរ»។

**លោក ចូន អរ. សែនឆែស** គ្រូគង្វាលរៀមច្បង នៅក្រុមជំនុំ High Pointe Baptist Church, Austin, នៅទីក្រុងតិចសាស (Texas)។

# តើមានរឿងអ្វីកើតឡើង ប្រសិនបើខ្ញុំមិនមានអារម្មណ៍ ចង់ទៅព្រះវិហារ?

## សំណួរសម្រាប់ក្រុមជំនុំ

*តើខ្ញុំអាចស្រឡាញ់សមាជិកក្រុមជំនុំដោយពួកគេមានបក្សនយោបាយខុសគ្នាបានដោយរបៀបណា? លោក យ៉ូណាថាន់ លីមែន និង លោក អេនឌី ណាសេលី*

*តើមានរឿងអ្វីកើតឡើង ប្រសិនបើខ្ញុំមានមានចិត្តចង់អធិស្ឋាន? លោក ចន អនវ៉ូដែកវ៉ា*

*តើមានរឿងអ្វីកើតឡើង ប្រសិនបើខ្ញុំមិនមានអារម្មណ៍ចង់ទៅព្រះវិហារ? លោក ហ្គាន់ណ័រ ហ្គាន់ឌ័រសិន*

*តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំបាក់ទឹកចិត្តក្នុងការផ្សាយដំណឹងល្អ? លោក អ៊ីសាក់ អាដាំស៍*

*តើឥឡូវនេះខ្ញុំគួរធ្វើអ្វីបន្ទាប់ទៀត នៅពេលដែលខ្ញុំក្លាយជាគ្រីស្ទបរិស័ទហើយ? លោក សែម អែមម៉ាឌី*

*ហេតុអ្វីបានជាខ្ញុំត្រូវទៅចូលរួមក្នុងក្រុមជំនុំ? លោក ម៉ាក ឌិវ័រ*

# តើមានរឿងអ្វីកើតឡើង ប្រសិនបើខ្ញុំមិនមានអារម្មណ៍ ចង់ទៅព្រះវិហារ?

លោក ហ្គាន់ណ័រ ហ្គាន់ឌ័រសិន
Gunner Gundersen

អង្គការ សកម្មភាព កម្ពុជា
actioncambodia.org
ផ្លូវពិត
plovpit.com

*តើមានរឿងអ្វីកើតឡើង ប្រសិនបើខ្ញុំមិនមានអារម្មណ៍ចង់ទៅព្រះវិហារ?*
*What If I Don't Feel Like Going to Church?*
By: Gunner Gundersen
Copyright © 2020 by 9Marks
Published by Crossway
1300 Crescent Street
Wheaton, Illinois 60187
This edition in Khmer © 2026

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org

ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ លោក ខែម បូឡុង

ជំនួយការអ្នកបកប្រែ៖ លោក ឈាង បូរ៉ា

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ឯក ធីម៉ូថេ, លោក ស៊ូ ទិត្យ, លោក ង៉ែត វិទូ, លោក ជា ពន្លឺ, លោកស្រី ឡូញ ស្រីរដ្ឋ និងលោកស្រី ចារ ប៊ុនរី

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក ខែម បូឡុង

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួលឆ្នាំ២០១៤ (គកស), ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ (គគខ), ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូល យើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

For ordering information please visit:

ប្រសិនបើចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖
www.plovpitshop.com

បោះពុម្ពលើកទី១ ចំនួន ៣.០០០ក្បាល គ.ស ២០២៦

ពួកអ្នកដែលជឿទាំងប៉ុន្មាន ក៏នៅជាមួយគ្នា . . .

កិច្ចការ ២:៤៤



ពេលវេលាសំខាន់បំផុតក្នុងការនៅក្នុងក្រុមជំនុំគឺ នៅពេលដែលលោកអ្នកមានអារម្មណ៍ថា មិនចង់ទៅព្រះវិហារ។

ខ្ញុំធ្លាប់បាននិយាយជាមួយគ្រីស្ទបរិស័ទបីនាក់ក្នុងមួយសប្ដាហ៍—ដែលពីរនាក់មានបញ្ហាជាមួយការបាក់ទឹកចិត្ត ហើយអ្នកទីបីបានឆ្លងកាត់ការបែកបាក់ដ៏ឈឺចាប់មួយ—ដែលគាត់លែងទៅជួបជុំជាមួយរាស្ត្ររបស់ព្រះទៀត។ មិនថាជាច្រើនសប្ដាហ៍ ឬច្រើនខែកន្លងផុតទៅនោះទេ អ្នកទាំងបីនោះក៏ឈប់មកព្រះវិហារនៅថ្ងៃអាទិត្យ។

ម្នាក់បាននិយាយថា វានឹងមិនមានការពេញចិត្តនោះទេ ដោយសារមិនមានទំនាក់ទំនងមួយដ៏

ច្បាស់លាស់។ ម្នាក់ទៀតបាននិយាយថា វានឹងពិបាក ដោយសារគាត់មិនចង់ឃើញសង្សារចាស់របស់គាត់នោះទេ។ ហើយម្នាក់ទៀតក៏បាននិយាយថា វានឹងមិនជួយអ្វីបាននោះទេ ដោយសារគាត់មិនមានបំណងចង់នៅទីនោះទៀតផង។

ខ្ញុំមិនមែននិយាយអំពីចំណុចនេះ ដើម្បីសម្រាលបន្ទុក ឬថ្កោលទោសពួកគេចំពោះអារម្មណ៍ដែលពួកគេបានធ្វើបែបនេះនោះទេ។ ខ្ញុំមិនមែនសរសេរទៅកាន់ពួកគេ ឬនិយាយអំពីពួកគេនោះទេ។ ខ្ញុំកំពុងសរសេរយ៉ាងសាមញ្ញទៅកាន់គ្រីស្ទបរិស័ទគ្រប់រូបដែលមានអារម្មណ៍ដូចជាពួកគេ ដែលថា (ដូចដែលខ្ញុំធ្លាប់មានអារម្មណ៍ពីមុនមកដែរ) ការជួបជុំគ្នាជាមួយរាស្ត្ររបស់ព្រះនឹងជាការមិនពេញចិត្ត មិនមានប្រយោជន៍ ឬគ្រាន់តែជារឿងដែលពិបាកនោះទេ។

ខ្ញុំកំពុងសរសេរអំពីអ្វីមួយដែលខ្ញុំបាននិយាយទៅកាន់មិត្តភក្តិទាំងបីរបស់ខ្ញុំ៖ ពេលវេលាសំខាន់បំផុតក្នុងការនៅក្នុងក្រុមជំនុំគឺនៅពេលដែលលោកអ្នកមានអារម្មណ៍ថា មិនចង់ទៅព្រះវិហារ។

គោលបំណងរបស់ខ្ញុំគឺសាមញ្ញណាស់៖ ខ្ញុំចង់ជំរុញចិត្តគ្រីស្ទបរិស័ទឲ្យមានការជួបជុំគ្នាយ៉ាងជាប់លាប់ មានអំណរ និងមានគោលបំណងជាក់លាក់។

ខ្ញុំកំពុងសរសេរទៅកាន់គ្រីស្ទបរិស័ទដែលស្រឡាញ់ព្រះយេស៊ូវ ហើយចង់ដើរតាមទ្រង់ ប៉ុន្តែជាអស់អ្នកដែលមានបញ្ហាក្នុងការយល់ ឲ្យតម្លៃ ឬស្វែងរកពេលសម្រាប់ទៅព្រះវិហារជាដើម។

## តើមានអ្វីនៅក្នុងអារម្មណ៍?

អារម្មណ៍អាចមានភាពស្មុគស្មាញ។ យើងទាំងអស់គ្នាដឹងហើយថា យើងមិនគួរធ្វើតាមអារម្មណ៍ដោយធ្វើឲ្យខ្លួនខ្វាក់មើលអ្វីផ្សេងទៀតមិនឃើញនោះទេ។ ដូចគ្នាដែរ អារម្មណ៍របស់យើងអាចបង្ហាញអំពីអ្វីដែលយើងពិតជាស្រឡាញ់ ចង់បាន ឬក៏គិតដល់។ ហើយដោយកូនសៀវភៅនេះនិយាយអំពីរបៀបដែលយើងមាន*អារម្មណ៍*ក្នុងការទៅព្រះវិហារ នេះជាចំណុចបីយ៉ាងក្នុងការចងចាំអំពីអារម្មណ៍របស់យើង។

ចំណុចទីមួយ *អារម្មណ៍របស់យើងមិនគួរកំណត់ជម្រើសឲ្យយើងនោះទេ*។ ប្រសិនបើយើងតែងតែធ្វើតាមអារម្មណ៍របស់ខ្លួន នោះគ្មានជីវិតអាពាហ៍ពិពាហ៍ណាអាចនៅគង់វង្សបានទេ ក្មេងៗនឹងញុំាតែស្ករគ្រាប់ ហើយការរត់ប្រណាំងម៉ារ៉ាតុងនឹងមិនមែនជារឿងសំខាន់អ្វីនោះទេ។ គ្រូអធិប្បាយ

ដែលមានអារម្មណ៍ថា មិនទាន់រៀបចំខ្លួន ហើយនៅយប់ថ្ងៃសៅរ៍ នឹងមិនមកនៅថ្ងៃអាទិត្យពេលព្រឹកនោះទេ គ្រីស្ទបរិស័ទដែលនៅក្រោមការបៀតបៀននឹងគ្រាន់តែសំងំនៅក្នុងផ្ទះ ហើយគ្រីស្ទបរិស័ទគ្រប់គ្នាដែលមិនសប្បាយចិត្តជាមួយអ្នកណាម្នាក់នៅក្នុងព្រះវិហារនឹងនៅតែបន្តចងគំនុំ ជំនួសឲ្យការមកព្រះវិហារជាមិនខាន។ ប៉ុន្តែ យើងដឹងថា យើងមិនគួរធ្វើអ្វីតាមអារម្មណ៍ ឬជៀសវាងអ្វីមួយដែលមិនស្រួលនោះដែរ។ បទគម្ពីរបានរម្លឹកយើងថា «មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវល្អដល់មនុស្ស តែចុងបំផុតនៃផ្លូវនោះ គឺជាសេចក្តីស្លាប់វិញ» (សុភាសិត ១៤:១២)។

ផ្ទុយទៅវិញ យើងដឹងថា បំណងប្រាថ្នាដ៏សំខាន់បំផុតរបស់យើង មានភាពស៊ីជម្រៅជាងអារម្មណ៍របស់យើងទៅទៀត។ ម្តាយដែលខកចិត្តម្នាក់ទំនងជាមានអារម្មណ៍ថា ចង់ចូលគេងសម្រាកពេលថ្ងៃដែលសមស្របមួយ ប៉ុន្តែផ្ទុយទៅវិញ គាត់នៅតែបន្តមើលកូនតូចៗរបស់គាត់។ ហេតុអ្វី? ពីព្រោះគាត់ចង់ការពារពួកគេជាងការដែលគាត់ចង់សម្រាក។ ដូចគ្នាផងដែរ គ្រប់គ្រីស្ទបរិស័ទដ៏ពិតម្នាក់ៗនឹងមានដួងចិត្តថ្មីសម្រាប់ព្រះ និងរាស្ត្ររបស់ព្រះអង្គដែលនៅបន្តលើកទឹកចិត្ត និងរុញយើងទៅ

មុខទៀត សូម្បីតែនៅពេលដែលយើងនឿយហត់ក៏ដោយ (ហេព្រើរ ៨:១០-១១)។ បំណងប្រាថ្នារបស់យើងមានស្រទាប់ ហើយជារឿយៗ បំណងប្រាថ្នាដ៏ជ្រាលជ្រៅបំផុតរបស់យើងតែងតែផ្ទុយគ្នាជាមួយអារម្មណ៍របស់យើងដែលឆ្លងកាត់។

ស្របពេលជាមួយគ្នាផងដែរ ភាគច្រើនអារម្មណ៍គឺជារោគសញ្ញានៃមូលហេតុអ្វីមួយ។ នៅពេលយើងមានអារម្មណ៍ថា យើងមិនចង់ទៅព្រះវិហារ នោះមានអ្វីមួយដែលជ្រៅជាងនេះទំនងជាកំពុងកើតឡើង—វាមិនមែនតែងតែបែបនេះរហូតទេ តែជាញឹកញាប់គឺបែបនេះ។ ដូចដែលព្រះគម្ពីរបានចែងថា «សេចក្តីដំបូន្មាននៅក្នុងចិត្តមនុស្ស នោះធៀបដូចជាអណ្តូងដ៏ជ្រៅ» (សុភាសិត ២០:៥)។ ដូច្នេះ ការដាក់ខ្លួនយើងនៅលើតុដែលកំពុងធ្វើប្រតិបត្តិការ ហើយអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធបើកចិត្តរបស់យើងតាមរយៈព្រះបន្ទូលរបស់ទ្រង់ នោះគឺជាការព្យាបាលដ៏មានសុវត្ថិភាពបំផុតសម្រាប់ព្រលឹងរបស់យើង។ «ពីព្រោះ ឯព្រះបន្ទូលនៃព្រះរស់នៅ ហើយពូកែផង ក៏មុតជាងដាវណាមានមុខ២ ទាំងធ្លុះចូលទៅ ទាល់តែកាត់ព្រលឹង និងវិញ្ញាណ ហើយសន្លាក់ និងខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិត ដែលចិត្តគិត ហើយដែលសំរេច

ដែរ» (ហេព្រើរ ៤:១២)។

## ការធ្វើរោគវិនិច្ឆ័យអំពីដួងចិត្ត

មានហេតុផលជាច្រើនដែលគ្រីស្ទបរិស័ទទំនងជាមិនមានអារម្មណ៍ចង់ទៅព្រះវិហារ។ ប៉ុន្តែ ប្រសិនបើលោកអ្នកដឹងអំពីមូលហេតុដែលនៅពីក្រោយភាពស្ទាក់ស្ទើរនោះ នោះលោកអ្នកនឹងស្គាល់ផ្លូវទៅមុខកាន់តែច្បាស់ថែមទៀត។ ការធ្វើរោគវិនិច្ឆ័យដ៏ត្រឹមត្រូវ គឺអាចជួយព្យាបាលបានពាក់កណ្ដាលរួចទៅហើយ—បើទោះបីការព្យាបាលនោះពិបាកក្នុងការអនុវត្តក៏ដោយ។ ដូច្នេះ តើអ្វីជាមូលហេតុរបស់លោកអ្នកដែលបញ្ហាក្នុងការមកព្រះវិហារ?

### *មូលហេតុខាងសាច់ឈាម*

គ្រីស្ទបរិស័ទមួយចំនួនមានបញ្ហាក្នុងការមកព្រះវិហារគឺដោយសារមានហេតុផលខាង*សាច់ឈាម* ដូចជា អស់កម្លាំង មានជំងឺ មានរោគ ឬការឈឺចាប់រ៉ាំរ៉ៃជាដើម។ ហើយបញ្ហាទាំងនេះអាចជាការមើលឃើញជាក់ស្ដែង ឬជាការមិនបានកត់សម្គាល់ ជាបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍ ឬអាចធ្វើរោគវិនិច្ឆ័យបាន ឬមិនអាចធ្វើបានផង

ដែរ។ ទោះបីជាយ៉ាងណាក្តី លោកអ្នកកំពុងមានបន្ទុកខាងឯសាច់ឈាម។ លោកីយ៍មួយនេះបានខូច ហើយលោកអ្នកក៏មិនមានកម្លាំងដូចម៉ាស៊ីនដែរ ហើយទោះបីជាពេលខ្លះ វិញ្ញាណរបស់លោកអ្នកបានប្រុងជាស្រេចមែន តែសាច់ឈាមខ្សោយទេ (ម៉ាថាយ ២៦:៤១)។

### *មូលហេតុខាងព្រលឹងវិញ្ញាណ*

ប្រហែលជាមូលហេតុមួយដែលខ្លាំងជាងគេគឺខាង*ព្រលឹងវិញ្ញាណ*។ លោកអ្នកកំពុងស្ថិតនៅទីងងឹត ហើយជំនឿគ្រីស្ទបរិស័ទហាក់បីដូចជាមិនមានពន្លឺរស្មីទៀតសោះ ឬមួយលោកអ្នកកំពុងរស់នៅក្នុងអំពើបាបដែលលោកអ្នកកំពុងលាក់បាំង។ ប្រហែលជាមានការជប់លៀងជាច្រើននៅលើលោកីយ៍នេះបានបង្អាក់ការស្រេកឃ្លានអាហារខាងព្រលឹងវិញ្ញាណរបស់លោកអ្នក ឬមួយក៏លោកអ្នកកំពុងឆ្លងកាត់ពេលវេលាដ៏សោះកក្រោះជាលើកដំបូងនៅក្នុងដំណើរជីវិតជាគ្រីស្ទបរិស័ទ។ ប្រហែលជាលោកអ្នកមានអារម្មណ៍ដូចជាអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងដែរ ដែលគាត់បានលើកឡើងថា «ឱព្រលឹងអញអើយ ហេតុអ្វីបានជាត្រូវ

បង្អោនចុះ ហើយមានសេចក្ដីរសាប់រសល់នៅក្នុងខ្លួនដូច្នេះ» (ទំនុកតម្កើង ៤២:៥)។

### *មូលហេតុខាងទំនាក់ទំនង*

ពេលខ្លះ បញ្ហាដែលប្រឈមនោះគឺជា*ទំនាក់ទំនង* ពោលគឺបញ្ហានៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ទំនាក់ទំនងមិត្តភាពប្រេះស្រាំ ឬក៏មានបុគ្គលិកលក្ខណៈឆ្គាំឆ្គងជាដើម។ ប្រហែលដោយសារលោកអ្នកនៅលីវ ឬនៅមេម៉ាយ/ពោះម៉ាយ ហើយលោកអ្នកមានអារម្មណ៍ថា លោកអ្នកចូលមិនចុះក្នុងចំណោមអ្នកមានគ្រួសារ។ ប្រហែលជាលោកអ្នកមិនយល់ស្របត្រង់ចំណុចណាមួយជាមួយអ្នកដឹកនាំ ហើយក៏មានភាពតានតឹងជាបន្តបន្ទាប់។ ប្រហែលជាមាននរណាម្នាក់មកចោទលទោស ឬស្ដីបន្ទោសឲ្យលោកអ្នក ហើយនៅពេលឃើញពួកគេ លោកអ្នកមានអារម្មណ៍ខឹង និងមានភាពអៀនខ្មាស។ ប្រហែលជាលោកអ្នកនឹងត្រូវគេបដិសេធ ឬបាត់បង់ទំនុកចិត្តពីអ្នកដទៃ ប្រសិនបើលោកអ្នកបង្ហាញអត្តសញ្ញាណរបស់ខ្លួនថាជាគ្រីស្ទបរិស័ទ។ ផ្ទុយទៅវិញ កណ្ឌគម្ពីរ ទំនុកតម្កើង ១៣៣:១ ខុសឆ្ងាយពីបទពិសោធរបស់លោកអ្នកណាស់ «មើល ដែលបង

ប្អូនទៅមូលជាមួយគ្នា ដោយចិត្តព្រមព្រៀង នោះជាការល្អ ហើយសមគួរយ៉ាងណាទៅ»។

## *មូលហេតុដែលសមហេតុសមផល*

ប្រហែលជាបញ្ហាចម្បងរបស់លោកអ្នកគឺជា*ហេតុផល*។ លោកអ្នករស់នៅឆ្ងាយ ឬការងារដែលលោកអ្នកធ្វើផ្លាស់ប្តូរម៉ោងពីមួយសប្តាហ៍ទៅមួយសប្តាហ៍។ ទំនងជាលោកអ្នកធ្វើដំណើរញឹកញាប់ ឬនៅចុងសប្តាហ៍គឺជាពេលវេលាដ៏មានតម្លៃ ដើម្បីធ្វើកិច្ចការសាលា ឬធ្វើការងារផ្សេងៗនៅជុំវិញផ្ទះរបស់លោកអ្នកផងដែរ។ សម្រាប់អ្នកម្តាយជាច្រើន ការដឹកកូនតូចៗទៅព្រះវិហារអាចជាការមួយដែលរញ៉េរញ៉ៃ និងអស់កម្លាំង ហើយការដែលប្រកែកជាមួយកូនធំៗរៀងរាល់សប្តាហ៍អាចធ្វើឲ្យលោកអ្នកមានអារម្មណ៍ថា ហត់ដូចជាការចាប់ក្តាមដាក់ចង្អេរអញ្ចឹង។ មិនថាស្ថានភាពបែបណានោះទេ ការទៅ និងការមកពីព្រះវិហារគឺជារឿងពិបាកណាស់។

## *មូលហេតុនៃចំណង់ចំណូលចិត្ត*

មានបញ្ហាខ្លះគឺមានជាប់ទាក់ទងនឹង*ចំណង់ចំណូលចិត្ត*។ លោកអ្នកមិនចូលចិត្តបទភ្លេង កម្មវិធីថ្វាយបង្គំ របៀបដែលអ្នកចូលរួមស្លៀកពាក់ ឬក៏របៀបដែលអ្នកដឹកនាំធ្វើ។ លោកអ្នកប្រាថ្នាចង់ឲ្យសេចក្ដីអធិប្បាយបានខ្លីជាងនេះ លោកអ្នកចង់ឲ្យអ្នកចូលរួមរួសរាយជាងនេះ ឬម្ហូបអាហារល្អជាងនេះ។ ចំណង់ចំណូលចិត្តរបស់លោកអ្នកទំនងជាឆ្លុះបញ្ចាំងពីគោលការណ៍តាមព្រះគម្ពីរ ឬក៏ទំនងគ្រាន់តែជាការដែលលោកអ្នកជាមនុស្សរើសប៉ុណ្ណោះ។ ប៉ុន្ដែ មិនថាលោកអ្នកត្រូវ ឬខុសនោះទេ ការដែលលោកអ្នកតែងតែមានអារម្មណ៍ថា មានបញ្ហាបែបនេះគឺមិនមែនជាសញ្ញាល្អនោះទេ។

## *មូលហេតុនៃវប្បធម៌*

ចំណង់ចំណូលចិត្តរបស់យើងមួយចំនួនគឺទាក់ទងនឹង*ផ្នែកវប្បធម៌*។ លោកអ្នកទំនងជាអ្នកធ្វើការដោយប្រើកម្លាំង ហើយចូលរួមនៅក្នុងព្រះវិហារដែលសមាជិកសុទ្ធតែជាអ្នកធ្វើការនៅការិយាល័យ ឬលោកអ្នកជាជនជាតិភាគតិចនៅក្នុងព្រះវិហារ ហើយមានតែមនុស្សពីរទៅបីនាក់

ប៉ុណ្ណោះដែលយល់ពីបរិបទនៃការរស់នៅរបស់លោកអ្នក។ លោកអ្នកទំនងជាជនចំណាកស្រុក ឬជាពលករមកពីប្រទេសផ្សេង ដើម្បីធ្វើការ ឬក៏ជាកូនបេសកជនដែលមានវប្បធម៌ខុសគ្នា។ មិនថាវាជារនាំងនៃផ្នែកភាសា ឬចំណុចផ្សេងៗទៀត ដែលធ្វើឲ្យលោកអ្នកមានអារម្មណ៍ថា ដូចជាអ្នកខាងក្រៅទេ ភាពខុសគ្នានៃផ្នែកវប្បធម៌ក៏អាចធ្វើឲ្យមានការលំបាកក្នុងការចូលរួមក្នុងព្រះវិហារផងដែរ។

### *មូលហេតុនៃការកម្សាន្ត*

មនុស្សមួយចំនួនមានបញ្ហាក្នុងការទៅព្រះវិហារ ដោយសារតែមូលហេតុនៃ*ការកម្សាន្ត*។ ចុងសប្ដាហ៍គឺជាពេលវេលាដ៏សំខាន់មួយសម្រាប់ការកម្សាន្ត ការធ្វើដំណើរបែបផ្សងព្រេង ការប្រកួតកីឡាផ្សេងៗ ដំណើរកម្សាន្ត ឬកម្មវិធីកីឡារបស់កូនៗ។ ដោយទើបឆ្លងផុតពេលវេលាដ៏មមាញឹកពេញមួយសប្ដាហ៍ ហើយមានឱកាសពិសេសទន្ទឹងរង់ចាំនៅខាងមុខដូចនេះ នោះវាពិបាកណាស់ក្នុងការឲ្យលោកអ្នកទុកអាទិភាពសម្រាប់ទៅព្រះវិហារ។

## *មូលហេតុចុះបេសកកម្ម*

ពេលខ្លះ គ្រីស្ទបរិស័ទមានពេលវេលាពិបាកក្នុងការទៅព្រះវិហារដោយសារតែមានការ*ណែនាំ*បន្តិចបន្តួចពីអ្នកដឹកនាំរបស់ខ្លួន។ យើងចង់ចូលរួម ចង់រួមចំណែក ហើយឲ្យខ្លួនយើងមានចំណែកនៅក្នុងព័ន្ធកិច្ចដែលព្រះគ្រីស្ទបានប្រទានមកដល់ពួកសិស្សរបស់ទ្រង់ (ម៉ាថាយ ២៨:១៨-២០)។ ប៉ុន្តែ ដោយសារខ្វះការដឹកនាំ នោះលោកអ្នកអាចមានអារម្មណ៍ថា ក្រុមជំនុំស្ថិតនៅជួរបន្ទាត់ចំហៀងជំនួសឲ្យជួរបន្ទាត់ខាងមុខវិញ។

## *មូលហេតុទាក់ទងនឹងគោលលទ្ធិ*

ពេលខ្លះ គ្រីស្ទបរិស័ទមិនអាចស្វែងរកព្រះវិហារដែលស្របតាម*គោលជំនឿរបស់ពួកគេបាន*។ ក្រុមជំនុំដែលលោកអ្នកចូលរួមទំនងជាអាចមានលំនាំដូចក្រុមជំនុំដើមរបស់លោកអ្នក ប៉ុន្តែមិនមែនជាក្រុមជំនុំដែលលោកអ្នកប្រាថ្នាចង់បាននោះទេ ដូច្នេះលោកអ្នកមានអារម្មណ៍ថា កំព្រាខាងឯព្រលឹងវិញ្ញាណ។ លោកអ្នកចង់ឲ្យក្រុមជំនុំរបស់ខ្លួនដើរដោយមានជំនឿមុតមាំ ប៉ុន្តែលោកអ្នកមិនចង់ឲ្យមានការមិនចុះសម្រុងគ្នាផង។ ចំណុចខុស

គ្នារបស់លោកអ្នកទំនងជារារាំងលោកអ្នកពីការភ្ជាប់ទំនាក់ទំនង ឬការបម្រើ ហើយលោកអ្នកទំនងជានឹងដឹងខ្លួនថា លោកអ្នកកំពុងស្ថិតនៅជាយខាង ឬស្ទើរតែដល់ចំណុចចាកចេញរួចហើយ។

## *ហេតុផលនៃប្រាជ្ញា*

គ្រីស្ទបរិស័ទផ្សេងទៀតពិបាកក្នុងការទៅព្រះវិហារ គឺដោយសារមានហេតុផលនៃ*ប្រាជ្ញា*។ សេចក្តីអធិប្បាយហាក់បីដូចជារាក់កំផែល និងដដែលៗ ហើយលោកអ្នកក៏ចេញទៅវិញដោយមិនមានចម្លើយចំពោះសំណួរដែលលោកអ្នកបានសួរ។ ប្រហែលដោយសារថ្នាក់បណ្ឌិត មានការគិតវិភាគ ការមានមិត្តភាពចម្រុះ ឬក៏ការមានប្រវត្តិស៊ីជម្រៅនៅក្នុងសាសនាផ្សេងៗដែលធ្វើឲ្យលោកអ្នកចង់គិតបែបស៊ីជម្រៅ។ ឬក៏ប្រហែលជាលោកអ្នកជាអ្នកដែលចូលចិត្តជំទាស់ ហើយតែងតែចង់ធ្វើអ្វីដែលផ្ទុយពីគេ។ លោកអ្នកបានប្តេជ្ញាចិត្តចំពោះព្រះគ្រីស្ទ ប៉ុន្តែក្រុមជំនុំរបស់លោកអ្នកមិនមែនជាកន្លែងដែលលោកអ្នកស្រួលចិត្តក្នុងការនាំមិត្តភក្តិដែលមិនមែនជាអ្នកជឿមកនោះទេ។

## *ហេតុផលនៃការផ្លាស់ប្តូរ*

មានហេតុផលនៃការ*ផ្លាស់ប្តូរ*មួយចំនួនដែលយើងត្រូវពិនិត្យមើលផងដែរ។ ពេលខ្លះ ការផ្លាស់ប្តូរទាំងនេះគឺជារឿងផ្ទាល់ខ្លួន—លោកអ្នកបោះជំហានចេញពីព័ន្ធកិច្ច ឬទៅរស់នៅទីក្រុងផ្សេង ឬក៏កំពុងស្វែងរកព្រះវិហារថ្មី។ ហើយពេលខ្លះទៀតគឺព្រះវិហារផ្ទាល់ដែលមានការផ្លាស់ប្តូរ។ មានគ្រូគង្វាលវ័យក្មេងដែលមកកាន់ដំណែង។ មិត្តភក្តិជិតស្និទ្ធចាកចេញពីព្រះវិហារ។ ព្រះវិហារផ្លាស់ប្តូរទីតាំង។ រដូវកាលនៃការផ្លាស់ប្តូរដ៏ចាំបាច់មួយនេះក៏អាចមានរយៈពេលយូរពេក ហើយក្លាយជាការរត់ប្រណាំងចម្ងាយឆ្ងាយដោយគ្មានខ្សែទីបញ្ចប់។

## *ហេតុផលផ្ទាល់ខ្លួន*

ជាចុងក្រោយ មនុស្សមួយចំនួនមានបញ្ហា*ផ្ទាល់ខ្លួន*ជាមួយក្រុមជំនុំ។ ប្រហែលជាលោកអ្នកត្រូវបានបំពានដោយ «អំណាចខាងឯវិញ្ញាណ» ដោយបានឃើញរឿងអាស្រូវរបស់គ្រូគង្វាល ឬបានស៊ូទ្រាំដោយសារព្រះវិហារមានការបែកបាក់។ នៅក្នុងស្ថានភាពមួយចំនួន លោកអ្នកទំនងជាទទួលរាប់រងនូវទំនួលខុសត្រូវ ប៉ុន្តែសូម្បីតែនៅពេលដែល

លោកអ្នកមិនមានកំហុសទាល់តែសោះ ក៏ការនោះនៅតែមានការឈឺចាប់ដែរ។ មិនថារបួសរបស់លោកអ្នកបណ្តាលមកពីអ្នកដទៃ ឬដោយសារខ្លួនឯងនោះទេ ក៏ហេតុផលផ្ទាល់ខ្លួនអាចធ្វើឲ្យយើងពិបាកក្នុងការស្រឡាញ់ក្រុមជំនុំ ទុកចិត្តលើក្រុមជំនុំ ឬសូម្បីតែទៅចូលរួមក្នុងក្រុមជំនុំផងដែរ។

---

យើងទាំងអស់គ្នាមានចរិតលក្ខណៈ ស្ថានភាព និងបញ្ហាប្រឈមខុសៗគ្នា។ ប៉ុន្តែ ខ្ញុំសង្ឃឹមថា ប្រភេទនៃមូលហេតុខាងលើទាំងអស់នេះនឹងចាប់ផ្តើមពិនិត្យមើលអំពីការគិតរបស់លោកអ្នក នៅពេលដែលលោកអ្នកវាយតម្លៃអំពីស្ថានភាពផ្ទាល់ខ្លួន។ លោកអ្នកអាចប្រើប្រាស់តារាង «ហេតុផលដែលខ្ញុំមានអារម្មណ៍មិនចង់ទៅព្រះវិហារ» ដើម្បីដាក់តាមលំដាប់ថ្នាក់ និងពន្យល់ពីមូលហេតុដែលស៊ីគ្នាជាមួយហេតុផលរបស់លោកអ្នកបំផុត។

| ហេតុផលដែលខ្ញុំមានអារម្មណ៍មិនចង់ទៅព្រះវិហារ | | |
|---|---|---|
| *លំដាប់ថ្នាក់* | *មូលហេតុ* | *ការពន្យល់* |
| | សាច់ឈាម | |
| | ព្រលឹងវិញ្ញាណ | |
| | ទំនាក់ទំនង | |
| | សមហេតុផល | |
| | ចំណង់ចំណូលចិត្ត | |
| | វប្បធម៌ | |
| | កម្សាន្ត | |
| | ចុះបេសកកម្ម | |
| | គោលលទ្ធិ | |
| | ប្រាជ្ញា | |

| ហេតុផលដែលខ្ញុំមានអារម្មណ៍មិនចង់ទៅព្រះវិហារ | | |
|---|---|---|
| *លំដាប់ថ្នាក់* | *មូលហេតុ* | *ការពន្យល់* |
| | ការផ្លាស់ប្តូរ | |
| | ផ្ទាល់ខ្លួន | |
| | ផ្សេងៗ | |

## ការស្វែងរកជំនួយ

ខ្ញុំមិនអាចគ្រាន់តែមើលពីស្ថានភាព ធ្វើរោគវិនិច្ឆ័យអំពីបញ្ហា ហើយធានាថា មានដំណោះស្រាយងាយស្រួលបាននោះទេ។ ជាញឹកញាប់ មិនមានដំណោះស្រាយណាមួយដែលងាយស្រួលសម្រាប់បញ្ហាដែលយើងប្រឈមនៅក្នុងក្រុមជំនុំឡើយ។ ប៉ុន្តែ ព្រះជាម្ចាស់បានសន្យាថា នឹងប្រទានប្រាជ្ញាដល់អស់អ្នកណាដែលទូលសូម «តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ» (យ៉ាកុប ១:៥)។ ដូច្នេះ តើយើងអាចស្វែងរកប្រាជ្ញាបែបនេះ

## នៅទីណាបានក្នុងការបន្តដំណើរទៅមុខទៀត?

### *ព្រះបន្ទូលរបស់ព្រះ*

ទីកន្លែងចម្បងក្នុងការស្វែងរកប្រាជ្ញា គឺជាព្រះបន្ទូលរបស់ព្រះ ដែលអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងបានសរសើរថា «ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវទូលបង្គំផង» (ទំនុកតម្កើង ១១៩:១០៥)។ បទគម្ពីរកើតចេញពីព្រះតម្រិះដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់ មានប្រយោជន៍សម្រាប់បង្រៀន ប្រដៅតម្រង់ និងបង្ហាត់យើង ដើម្បីឲ្យយើងអាច «មានគ្រប់ទាំងចំណេះសម្រាប់នឹងធ្វើការល្អគ្រប់មុខ» (២ធីម៉ូថេ ៣:១៦-១៧)។ នៅពេលផ្លូវដែលយើងកំពុងដើរសំដៅទៅមុខហាក់បីដូចជាមានថ្ម ហើយមានភាពមិនច្បាស់លាស់ សូមឲ្យយើងបានទឹកដល់ខគម្ពីរនេះថា៖

> ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត
> កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ
> ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ
> នោះទ្រង់នឹងដំរង់អស់ទាំង
> ផ្លូវច្រករបស់ឯង
> (សុភាសិត ៣:៥-៦) ។

ដូចជាទឹកមួយដំណក់ៗអាចធ្វើឲ្យថ្មសឹករលោងបាន នោះការឲ្យដួងចិត្តរបស់លោកអ្នកបានលិចចូលទៅក្នុងសេចក្តីពិតនឹងកែប្រែទម្លាប់របស់លោកអ្នកទៅតាមពេលវេលាបន្តិចម្តងៗផងដែរ។

## *មិត្តភក្តិដែលយល់ពីយើង*

នៅក្នុងកណ្ឌគម្ពីរ សុភាសិត ១៨:១ បានចែងថា «អ្នកណាដែលញែកខ្លួនចេញពីអ្នកដទៃ នោះជាអ្នករកបំពេញតែខ្លួនឯងទេ ហើយក៏មានចិត្តគ្នាន់ក្នាញ់ទាស់នឹងអស់ទាំងសេចក្តីដែលមានទំនង»។ នៅពេលដែលយើងមានបញ្ហាជាមួយក្រុមជំនុំ នោះវាងាយស្រួលណាស់ក្នុងការដែលយើងជ្រើសរើសយកការខកចិត្តដោយស្ងៀមស្ងាត់ ជាជាងការមានទំនាក់ទំនងជាមួយគ្នាដែលមានសុខភាពល្អ។ ប៉ុន្តែការសម្រេចចិត្តគិតម្នាក់ឯងបែបនេះពិតជាគ្រោះថ្នាក់ណាស់ ពីព្រោះអំពើបាបមានពេញទៅដោយឧបាយកល ហើយដូចជាដីឥដ្ឋនៅក្រោមកម្តៅថ្ងៃ នោះដួងចិត្តរបស់យើងក៏ងាយរឹងរូសដូចគ្នាយ៉ាងនោះដែរ (អេភេសូរ ៤:១៤, ហេព្រើរ ៣:១៣)។

ផ្ទុយទៅវិញ កណ្ឌគម្ពីរ សាស្តា ៤:៩-១០ បានបង្រៀនយើងអំពីប្រាជ្ញាក្នុងការដែលយើងរួម

ចំណែកជាមួយអ្នកដទៃទៀត «មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង...ដ្បិតបើដួល នោះម្នាក់នឹងជ្រោងគ្នាឡើងវិញ តែវរហើយ អ្នកណាដែលដួលក្នុងកាលដែលនៅតែម្នាក់ឯង ឥតមានគ្នានឹងជួយជ្រោងឡើងវិញ»។ មានមិត្តភក្តិដែលមិនមានភាពចាស់ទុំ ដែលពួកគេគ្រាន់តែឲ្យលោកអ្នកនិយាយចេញ ហើយនិយាយដើមគេប៉ុណ្ណោះ ហើយក៏មានមិត្តភក្តិដែលមានភាពចាស់ទុំដែលគេអាចស្តាប់ពីបញ្ហារបស់លោកអ្នកបានយ៉ាងល្អ ហើយផ្តល់យោបល់ដែលមានពេញដោយប្រាជ្ញាដែលមានមូលដ្ឋានក្នុងព្រះបន្ទូលរបស់ព្រះផងដែរ។ សូមស្វែងរកមិត្តភក្តិដែលមានភាពចាស់ទុំបែបនេះ ជាមិត្តភក្តិដែលយល់ពីលោកអ្នក ហើយចែកចាយអំពីបញ្ហារបស់លោកអ្នកជាមួយពួកគេចុះ។ «សេចក្តីដំបូន្មាននៅក្នុងចិត្តមនុស្ស នោះធៀបដូចជាអណ្តូងដ៏ជ្រៅ តែមនុស្សដែលមានយោបល់ គេនឹងដងឡើងបាន» (សុភាសិត ២០:៥)។

### *អ្នកដឹកនាំដែលព្រះប្រទានមក*

វាហាក់បីដូចជាចម្លែកក្នុងការណែនាំលោកអ្នកទៅកាន់អ្នកដឹកនាំនៅក្នុងក្រុមជំនុំ នៅពេលដែល

លោកអ្នកកំពុងមានបញ្ហាជាមួយក្រុមជំនុំនោះឯង។ មានស្ថានភាពជាក់លាក់មួយចំនួនដែលអ្នកដឹកនាំបង្ហាញថា ពួកគាត់មិនអាចទុកចិត្តបាន ហើយយើងក៏មិនគួរយកគំរូតាមផងដែរ (អេសេគាល ៣៤:១-២៤, ទីតុស ១:១០-១៦)។ ប៉ុន្តែ បទគម្ពីរក៏បានបង្ហាញឲ្យឃើញអំពីចក្ខុវិស័យសម្រាប់ជីវិតក្រុមជំនុំដែលមានអ្នកដឹកនាំដែលជាអ្នកបម្រើដែលកោតខ្លាចព្រះដែលបានយកចិត្តទុកដាក់សម្រាប់ក្រុមអ្នកជឿដែលបានបានគោរព ការទុកចិត្ត ហើយការដែលដើរតាមពួកគាត់ក្នុងនាមជាអ្នកគង្វាលដែលព្រះបានចាត់បញ្ជូនមក (កិច្ចការ ២០:២៨, ហេព្រើរ ១៣:៧, ១ពេត្រុស ៥:១-៥)។

ដោយយោងតាមចក្ខុវិស័យនេះ ព្រះជាម្ចាស់បានមានបន្ទូលថា «ចូរស្តាប់តាម ហើយចុះចូលនឹងពួកអ្នក ដែលនាំមុខអ្នករាល់គ្នាចុះ ដើម្បីឲ្យអ្នកទាំងនោះបានថែរក្សាព្រលឹងអ្នករាល់គ្នាដោយអំណរ មិនមែនដោយស្រែកថ្ងូរទេ ដ្បិតបើត្រូវស្រែកថ្ងូរ នោះបង់ប្រយោជន៍ដល់អ្នករាល់គ្នាហើយ ពីព្រោះអ្នកទាំងនោះថែរក្សា ហាក់ដូចជានឹងត្រូវរាប់រៀបទូលដល់ទ្រង់វិញ» (ហេព្រើរ ១៣:១៧)។ ដូច្នេះ សូមអនុញ្ញាតឲ្យអ្នកដឹកនាំខាងព្រលឹងវិញ្ញាណរបស់លោកអ្នកជួយលោកអ្នកឲ្យបានយល់ពីជំហានបន្ទាប់

ទៅមុខទៀត ខណៈពេលដែលលោកអ្នកចាប់ផ្តើមចូលរួមជាមួយក្រុមជំនុំម្តងទៀត។

---

ទាំងនេះគឺជារបៀបមូលដ្ឋានគ្រឹះបីយ៉ាងដែលលោកអ្នកអាចស្វែងរកជំនួយ ខណៈពេលដែលយើងកំពុងតស៊ូជាមួយបំណងប្រាថ្នារបស់យើងក្នុងការមិនចង់ទៅព្រះវិហារ (១) សិក្សាអំពីព្រះបន្ទូលរបស់ព្រះ (២) សូមនិយាយជាមួយមិត្តភក្តិដែលយល់ពីយើង (៣) សូមចែករំលែកជាមួយអ្នកដឹកនាំដែលព្រះបានប្រទានមក។

មកដល់ចំណុចនេះ យើងបានស្វែងយល់អំពីដួងចិត្តរបស់យើង ហើយបានរម្លឹកខ្លួនយើងឲ្យចេះស្វែងរកជំនួយ។ ឥឡូវនេះ ដល់ពេលដែលយើងត្រូវនិយាយអំពីក្រុមជំនុំវិញម្តង។

## តើក្រុមជំនុំជាអ្វី?

នៅក្នុងព្រះគម្ពីរសញ្ញាថ្មីបានប្រើប្រាស់នូវរូបភាពបីយ៉ាង សម្រាប់ក្រុមជំនុំដែលសង្កត់ធ្ងន់អំពីភាពរួបរួមគ្នារបស់យើង៖ ជាគ្រួសារនៃបងប្អូនបង្កើត ជា

ផ្នែកផ្សេងៗនៃរូបកាយតែមួយ និងជាដំណាក់នៃព្រះដែលមានថ្មរស់។ ក្រុមជំនុំគឺជា «ដំណាក់ព្រះ» «រូបកាយព្រះគ្រីស្ទ» និងជា «លំនៅនៃព្រះដោយនូវព្រះវិញ្ញាណ» ដែលបានសង់ឡើងដោយ «ថ្មរស់» (១កូរិនថូស ១២:១២-២៧, អេភេសូរ ២:២១-២២, ៤:១៥-១៦, ១ធីម៉ូថេ ៣:១៥, ១ពេត្រុស ២:៥)។ អត្ថន័យនៅទីនេះបានបង្ហាញយ៉ាងជាក់លាក់៖ គ្រួសាររស់នៅជាមួយគ្នា ផ្នែកផ្សេងៗនៃរូបកាយសហការជាមួយគ្នា ហើយដំណាក់នៃព្រះដែលមានថ្មរស់ក៏ដាក់ត្រួតស៊ីដែរ។

មនុស្សមួយចំនួនបានប្រើប្រាស់សេចក្តីពិតទាំងនេះក្នុងការកាត់បន្ថយការទៅព្រះវិហារ។ ពួកគេនិយាយថា «ក្រុមជំនុំគឺជាមនុស្ស មិនមែនជាទីកន្លែងនោះទេ»។ «វាគឺជាផ្នែកមួយនៃក្រុមជំនុំ មិនមែនជាការ*ទៅ*ព្រះវិហារនោះទេ»។ ប៉ុន្តែ ផ្ទុយពីការបន្ទាបនូវចំណុចទាំងនេះ រូបភាពទាំងនេះក៏បានបង្ហាញឲ្យឃើញពីភាពស្រស់ស្អាត និងអត្ថប្រយោជន៍នៃការជួបជុំគ្នាជាមួយបងប្អូនរួមជំនឿផ្សេងទៀតដែរ។

រាស្ត្ររបស់ព្រះតែងតែត្រូវបានគេសម្គាល់ បានដឹង និងបង្កើតជាថ្មីដោយការជួបជុំគ្នាយ៉ាងទៀតទាត់ និងមានសណ្តាប់ធ្នាប់ (ហេព្រើរ ១០:២៤-២៥)។ រូបកាយដែលមិនជាប់នៅជាមួយគ្នាគឺប្រៀបដូចជា

ឃ្លាំងផលិតដៃជើងសិប្បនិមិត្តអញ្ចឹង ហើយប្រសិនបើគ្រួសារណាមួយមិនដែលបរិភោគអាហារពេលល្ងាចជាមួយគ្នា ឬមិនដែលមានការណាត់ចេញក្រៅ ឬមានការរួបរួមជួបជុំគ្នាទេ គ្រួសារនោះក៏មិនមែនជាគ្រួសារដែលមានសុខភាពល្អ ឬមានសុភមង្គលឡើយ។ គ្មានព្រះវិហារណាមួយអាចឈររឹងមាំបានឡើយ ប្រសិនបើថ្មដែលធ្វើនោះមិនស្អិតជាប់លើគ្នា។ ការដែលជួបជុំជាមួយគ្នាដោយផ្ទាល់ គឺមានភាពសំខាន់យ៉ាងដូច្នោះដែរ។

ជាការពិតណាស់ លោកអ្នកអាចស្តាប់ចម្រៀងគ្រីស្ទបរិស័ទ និងសេចក្តីអធិប្បាយមួយចំនួនតាមអ៊ីនធើណិតម្តងក្នុងមួយសប្តាហ៍ ប៉ុន្តែវាមិនមែនជាការប្រកបគ្នាមុខទល់នឹងមុខ ឬមានអ្នកមើលថែព្រលឹងវិញ្ញាណផ្ទាល់ខ្លួន ឬការមានចំណែកក្នុងការទទួលនំប៉័ង និងស្រាទំពាំងបាយជូរដែលតំណាងឲ្យរូបកាយ និងព្រះលោហិតរបស់ព្រះយេស៊ូវឡើយ។ លោកអ្នកអាចអានព្រះគម្ពីរ ហើយអធិស្ឋានដោយខ្លួនឯង ប៉ុន្តែលោកអ្នកមិនបានឮសំឡេងសេចក្តីបង្រៀនពីអ្នកគង្វាលរបស់អ្នកផ្ទាល់ទេ ហើយក៏មិនបានឮពីសេចក្តីកម្សាន្តចិត្ត និងការកែតម្រង់ពីគាត់ដែរ។ លោកអ្នកថែមទាំងអាចទៅព្រះវិហារផ្សេងទៀត ដោយសារលោកអ្នកមិនពេញចិត្តនឹងព្រះវិហារ

របស់ខ្លួន ប៉ុន្តែនោះមិនមែនជាការដែលលោកអ្នកប្រព្រឹត្តចំពោះក្រុមជំនុំតាមតំបន់ដែលជាសហគមន៍នៃសេចក្តីសញ្ញាឡើយ។

## *គ្រួសារនៃសេចក្តីសញ្ញា*

នៅគ្រប់គ្រួសារ គ្រប់រូបកាយ ឬក្រុមជំនុំដែលមានសុខភាពល្អ គឺតែងតែមានគ្រឿងផ្សំសម្ងាត់មួយ៖ នោះគឺជាការប្តេជ្ញាចិត្តចុះចូលចំពោះផ្នែកនីមួយៗ។ គ្រួសារដែលមានសុខភាពល្អគឺមានទំនាក់ទំនងស្និទ្ធស្នេហជាមួយគ្នា។ ចំណែករូបកាយដែលខ្លាំងគឺដោយសារគ្រប់ផ្នែកសហការ និងបន្តដំណើរទៅមុខជាមួយគ្នាដែរ។ រឹងអគារដែលរឹងមាំអាចគង់នៅបានក៏ដោយសារផ្នែកនៅជាប់ជាមួយគ្នាដែរ។

សេចក្តីសញ្ញាត្រូវបានធ្វើឡើងក្នុងពេលពិបាកៗ មិនមែនក្នុងពេលល្អ ឬពេលមានភាពងាយស្រួលនោះទេ។ នៅក្នុងពេលវេលាល្អៗ យើងហាក់បីដូចជាមិនត្រូវការសេចក្តីសញ្ញាឡើយ ពីព្រោះយើងហាក់ដូចជាអាចធ្វើបាន ហើយនៅជាប់ជាមួយអារម្មណ៍របស់យើងតែមួយមុខវិញ។ សេចក្តីសញ្ញានៃសហគមន៍ជួយទប់យើងនៅពេលដែលយើងមានបញ្ហា ហើយលើកយើងឡើងនៅពេលដែលយើង

ដួលចុះ។ ពួកគាត់លើកទឹកចិត្តយើងនៅពេលដែលយើងនឿយហត់ ហើយដាស់យើងនៅពេលដែលងោកងុយខាងឯវិញ្ញាណ។ ពួកគាត់នាំយើងចេញពីការមានទំនោរទៅរកខ្លួនឯង ហើយហៅយើងឲ្យមានការប្ដេជ្ញាចិត្ត និងមានទំនួលខុសត្រូវ។ ពួកគាត់គឺជាទីកន្លែងដ៏ស្រស់ស្អាតនៃសហគមន៍គ្រីស្ទបរិស័ទ ជាកន្លែងដែលយើងអាចរីកលូតលាស់ជាមួយព្រះអង្គ។

នៅក្នុងព្រះគម្ពីរមានពេញដោយការតាំងសេចក្ដីសញ្ញា ការយកព្រះទ័យទុកដាក់របស់ព្រះចំពោះរាស្ត្ររបស់ព្រះអង្គ ដើម្បីឲ្យការនោះអាចជួយឲ្យមានការប្ដេជ្ញាចិត្តចំពោះទ្រង់វិញដូចគ្នា។ ពួកជំនុំអាចកើតឡើងបានដោយសារព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង ដើម្បីលោះ និងសម្អាតយើងដោយព្រះលោហិតទ្រង់ ដែលការនោះបានបោះត្រាបញ្ជាក់ថា «សេចក្ដីសញ្ញាថ្មី» (ហេព្រើរ ៨:១-១០:២៤)។ គ្រប់គ្រីស្ទបរិស័ទពិតប្រាកដទាំងអស់ មានចំណែកនៅក្នុងសេចក្ដីសញ្ញានេះ ដែលមានន័យថា អំពើបាបរបស់យើងបានអត់ទោសឲ្យតាមរយៈការសុគតរបស់ព្រះគ្រីស្ទក្នុងនាមជាអ្នករងទោសជំនួសចំពោះរបស់យើង ហើយយើងទទួលបានការផ្លាស់ប្ដូរដួងចិត្តខាងវិញ្ញាណ ដើម្បីឲ្យយើងអាចស្រឡាញ់ព្រះ

អង្គ និងបម្រើអ្នកដទៃទៀត ព្រមទាំងក្លាយជាផ្នែកមួយនៃគ្រួសារខាងឯព្រលឹងវិញ្ញាណរបស់ព្រះ ដោយមានគ្រប់ទាំងសិទ្ធិ និងអភ័យឯកសិទ្ធិ ក៏ដូចជាទំនួលខុសត្រូវទាំងអស់ផងដែរ។

នៅពេលខ្ញុំជានិស្សិតឆ្នាំទី២ ខ្ញុំបានក្លាយជាអ្នកសម្របសម្រួលកីឡានៅក្នុងសកលវិទ្យាល័យគ្រីស្ទបរិស័ទដ៏តូចមួយ។ ខ្ញុំបានរៀបចំការប្រកួត ការចុះឈ្មោះ រៀបចំកំណត់កាលវិភាគប្រកួត ចាត់ចែងអាជ្ញាកណ្ដាលគ្រប់កីឡា និងដោះស្រាយគ្រប់ទាំងបញ្ហាទាំងអស់ដែលមាន។ កាលនៅជំទង់ ខ្ញុំធ្លាប់ធ្វើជាអ្នករត់កាសែត និងកាត់ស្មៅនៅវិទ្យាល័យរបស់ខ្ញុំ ប៉ុន្តែនេះគឺជាលើកទីមួយដែលខ្ញុំបានធ្វើការងារទាក់ទងនឹងមនុស្សរាប់រយនាក់ និងមានបញ្ហាប្រឈមធំៗជាច្រើន។ ជាញឹកញាប់ ខ្ញុំមិនស្រណុកចិត្តនោះទេ។ ប៉ុន្តែ ខ្ញុំពិតជាបានរីកចម្រើន នៅពេលដែលខ្ញុំបានបម្រើដល់អ្នកដទៃទៀត។ ហេតុអ្វី? ដោយព្រោះខ្ញុំមានទំនួលខុសត្រូវ។

បើគ្មានតួនាទី និងការប្ដេជ្ញាចិត្តច្បាស់លាស់ទេ នោះជាធម្មតាបំណងប្រាថ្នាក្នុងការរីកចម្រើនរបស់យើងនឹងក្លាយជាគំនរជីកំប៉ុសនៃចេតនាល្អតែប៉ុណ្ណោះ។ មានមូលហេតុមួយដែលថា ហេតុអ្វីបានជាទាហានចុះឈ្មោះចូលបម្រើកងទ័ព និស្សិត

ចុះឈ្មោះចូលសាលារៀន និងដៃគូស្នេហាព្រមព្រៀងភ្ជាប់ពាក្យជាមួយជាដើម។ ការប្ដេជ្ញាចិត្តជួយយើងឲ្យបានចម្រើនកម្លាំងជាមុន ដោយការនោះនាំឲ្យយើងមានទំនួលខុសត្រូវចំពោះគ្នាទៅវិញទៅមកជាពិសេសនៅពេលដែលយើងមានអារម្មណ៍ថាមិនចង់ធ្វើវាក៏ដោយ។

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពួកអ៊ីស្រាអែលប្រារព្ធពិធីដ៏ពិសិដ្ឋ ដើម្បីបន្តការប្ដេជ្ញាចិត្តនៅក្នុងសេចក្ដីសញ្ញារបស់ពួកគេ។ នៅក្នុងក្រុមជំនុំក៏មានការប្រារព្ធពិធី ដើម្បីបន្តការប្ដេជ្ញាចិត្តនៅក្នុងសេចក្ដីសញ្ញាដែរ ពោលគឺពិធីលៀងព្រះអម្ចាស់។ ការទទួលពិធីនេះជាមួយគ្នាយ៉ាងទៀងទាត់ គឺជាការរម្លឹកថា យើងមានសេចក្ដីមេត្រីជាមួយព្រះតាមរយៈព្រះគ្រីស្ទ ហើយថា ព្រះអង្គនឹងយាងមកវិញយ៉ាងឆាប់ (១កូរិនថូស ១១:២៣-២៦)។ ប៉ុន្តែ សេចក្ដីសញ្ញាថ្មីមិនគ្រាន់តែធានាដល់យើងថា យើងបានផ្សះផ្សាជាមួយព្រះ និងជាមួយគ្នាទៅវិញទៅមកនោះទេ ការប្រារព្ធពិធីនេះក៏ជាការត្រាស់ហៅយើងឲ្យត្រឡប់មកឯការមានទំនួលខុសត្រូវផងដែរ។ វាងាយស្រួលក្នុងការដែលយើងងាយរអិលធ្លាក់ក្នុងការគិតថា ជាចម្បងការមានកម្មវិធីថ្វាយបង្គំគឺសម្រាប់ខ្ញុំ។ ប៉ុន្តែនេះគឺជាកម្មវិធីដ៏ពិសិដ្ឋដែលបានជួបជុំគ្នា ហើយ

ព្រះបានចម្អែត*យើងទាំងអស់គ្នា*ដោយព្រះគុណរបស់ទ្រង់ និងបន្តនូវភក្តីភាពរបស់យើងចំពោះព្រះអង្គ និងចំពោះគ្នាទៅវិញទៅមក។

លោកអ្នកឃើញទេ សេចក្តីសញ្ញាមានជាប់ទាក់ទងនឹងលោកអ្នក ប៉ុន្តែសេចក្តីសញ្ញាទាំងនេះមិនមែនអំពីលោកអ្នកនោះទេ។ សេចក្តីសញ្ញាគឺអំពី*យើង*ទាំងអស់គ្នា។

*សេចក្តីសញ្ញាមិនមែនអំពីលោកអ្នកទេ*

ខ្ញុំយល់ត្រង់ចំណុចនេះហើយ។ វាអាចពិបាកក្នុងការយល់។ ក្រុមសរសើរតម្កើងមិនបានជ្រើសរើសចម្រៀងចេញពីបញ្ជីចម្រៀងផ្ទាល់ខ្លួនរបស់លោកអ្នកទេ។ គ្រូគង្វាលក៏មិនមានពេលវេលា និងធនធានគ្រប់គ្រាន់ក្នុងការរៀបចំយកចិត្តទុកដាក់លើសេចក្តីអធិប្បាយឲ្យបានល្អដូចជាអ្នកថ្លែងសុន្ទរកថារបស់នាយករដ្ឋមន្ត្រីដែរ។ សមាជិកនៅក្នុងក្រុមជំនុំទំនងជាមិនមានការរួមបញ្ចូលសមាជិកបានល្អដូចជា ពួកចាស់ទុំក្នុងការណែនាំលោកអ្នក អ្នកជឿវ័យក្មេងជាងក្នុងការជំរុញចិត្ត អ្នកជឿមានភាពពេញវ័យខាងព្រលឹងវិញ្ញាណក្នុងការប្រឹក្សាយោបល់ជាមួយលោកអ្នក អ្នកពូកែស្វាគមន៍ក្នុង

ការស្វាគមន៍លោកអ្នកឲ្យចូលរួម និងពួកអ្នកជឿដែលតាមសួរសុខទុក្ខលោកអ្នកជាដើម។

ប៉ុន្តែ ប្រសិនបើក្រុមជំនុំរបស់លោកអ្នកជឿលើព្រះគម្ពីរ ហើយអធិប្បាយអំពីដំណឹងល្អ ហើយអនុវត្តតាមសេចក្ដីបង្គាប់ ព្រមទាំងបម្រើគ្នាទៅវិញទៅមក នោះក្រុមជំនុំរបស់លោកអ្នកគឺពួកចាស់ទុំដែលជាពួកបរិសុទ្ធហើយ ហើយពួកបរិសុទ្ធទាំងនោះគឺជាបងប្អូនប្រុសស្រី ឪពុកម្ដាយរបស់លោកអ្នក ជាអ្នករួមដំណើរតាមផ្លូវយ៉ាងខ្សោះខ្សោយតាមផ្លូវនៅទីរហោស្ថានជាមួយគ្នា ដែលនៅឆ្ងាយពីស្រុកអេស៊ីព្ទ ដោយបានដឹកនាំដោយបង្គោលពពក និងបង្គោលភ្លើង ព្រមទាំងសម្លឹងមើលទៅឯទឹកដីសន្យាហើយ (និក្ខមនំ ១៣:២១-២២; ហេព្រើរ ១២:១-២)។

វាមិនមែនជាការធ្វើដំណើរតែឯងនោះទេ ប៉ុន្តែជាការធ្វើដំណើរជាក្រុមដែលមានគោលបំណងច្បាស់លាស់។

លោកអ្នកឃើញទេ មនុស្សទាំងនោះដែលលោកអ្នកចង់ឲ្យពួកគាត់តាមរកលោកអ្នក បារម្ភអំពីលោកអ្នក សួរនាំអំពីលោកអ្នក ក៏ត្រូវការលោកអ្នកប្រព្រឹត្តចំពោះពួកគាត់ដូចគ្នាដែរ (កាឡាទី ៦:៩-១០)។

គ្រូគង្វាលដែលលោកអ្នកស្រមៃចង់ឲ្យគាត់

អធិប្បាយបានល្អជាងនេះ ក៏ទំនងជាកំពុងអធិស្ឋាន ចង់ឲ្យលោកអ្នកអាចធ្វើជាអ្នកស្តាប់ដ៏ល្អម្នាក់ផងដែរ (ម៉ាកុស ៤:៣-៨; យ៉ាកុប ១:២២-២៥)។ មនុស្ស ដែលមានអំណោយទានទាំងនោះដែលលោកអ្នក ត្រូវការសេចក្តីស្រឡាញ់ពីពួកគាត់ ពួកគាត់ក៏ត្រូវ ការសេចក្តីស្រឡាញ់យ៉ាងពិសេសពីលោកអ្នកផង ដែរ (អេភេសូរ ៤:១៥-១៦)។ សូម្បីតែអស់អ្នកដែល លោកអ្នកគិតថា រំខាន ឬមិនមែនជាជំនួយសម្រាប់ លោកអ្នក ឬឆ្គាំឆ្គង ក៏ពួកគាត់មិនត្រូវការការរិះគន់ ពីលោកអ្នកដែរ ប៉ុន្តែពួកគាត់ត្រូវការលោកអ្នកក្នុង នាមជាដៃគូនៅក្នុងដំណឹងល្អ។

ហើយលោកអ្នកមិនអាចធ្វើការទាំងអស់នោះ បានទេ ប្រសិនបើលោកអ្នកមិនបានបង្ហាញខ្លួននៅ ព្រះវិហារ។

## អំណាចនៃការមានវត្តមាន

ឥឡូវនេះ ខ្ញុំជាគ្រូគង្វាលម្នាក់នៅក្នុងក្រុមជំនុំរបស់ ខ្ញុំ។ អ្នកបម្រើនៅទីនេះពីមុនខ្ញុំ បានបម្រើយ៉ាង ស្មោះត្រង់អស់រយៈពេលជាង៣០ឆ្នាំ។ មានមនុស្ស ជាច្រើនបានប្រាប់ខ្ញុំអំពីដំណើររឿងខុសៗគ្នាអំពី ឥទ្ធិពលរបស់គាត់នៅក្នុងជីវិតរបស់ពួកគេ ប៉ុន្តែ

ដែលសំខាន់ជាពិសេសដែលពួកគាត់ទាំងអស់គ្នាបាននិយាយគឺដូចគ្នា។ ដោយពឹងផ្អែកលើដំណើររឿងរបស់ពួកគាត់ ខ្ញុំមានចំណងជើងសម្រាប់ជីវប្រវត្តិរបស់គាត់ថា៖ *អ្នកនៅទីនោះ*។

- «អ្នកនៅទីនោះ នៅពេលកូនស្រីរបស់យើងទើបនឹងសម្រាល»។
- «អ្នកបានរៀបចំកម្មវិធីបុណ្យសពរបស់លោកតាខ្ញុំ»។
- «អ្នកបានមកសួរសុខទុក្ខ នៅពេលកូនប្រុសរបស់យើងបានសម្លាប់ខ្លួន»។
- «អ្នកបានធ្វើបុណ្យជ្រមុជទឹកឲ្យខ្ញុំ និងប្រពន្ធរបស់ខ្ញុំ»។
- «អ្នកបានចែកចាយដំណឹងល្អជាមួយឪពុករបស់ខ្ញុំ»។
- «អ្នកបានរៀបចំកម្មវិធីអាពាហ៍ពិពាហ៍របស់ពួកយើង»។
- «អ្នកបានឃំជាមួយពួកយើងនៅពេលដែលគ្រួសារយើងមានជំងឺមហារីករើឡើងវិញ»។

«អ្នកនៅទីនោះ» ជាពាក្យ៤ម៉ាត់ដ៏ល្អបំផុតដែលមិត្តម្នាក់អាចស្ដាប់ឮ៖ *អ្នកបានមក*។ *អ្នកបានជួយ*។ *អ្នកបានបង្ហាញខ្លួន*។ *អ្នកនៅនោះ*។

ស្ដេច សាឡូម៉ូន បានមានបន្ទូលប្រាប់យើងថា «អ្នកមួយដែលនៅជិតខាងខ្លួន នោះវិសេសជាងបងប្អូនដែលនៅឆ្ងាយវិញ» (សុភាសិត ២៧:១០)។ ព្រះយេស៊ូវមិនគ្រាន់តែព្យាបាលអ្នកកើតឃ្លង់នោះទេ ប៉ុន្តែព្រះអង្គបាន «ពាល់» គាត់តែម្តង (ម៉ាថាយ ៨:៣)។ សាវ័ក ប៉ុល មានចិត្តសង្វាត រឭកចង់ «ឃើញមុខ» អ្នកនៅក្នុងក្រុមជំនុំគាត់ជាខ្លាំង (១ថែស្សាឡូនីច ២:១៧; ៣:១០)។ សាវ័ក យ៉ូហាន ក៏ប្រាថ្នាចង់បានទំនាក់ទំនងផ្ទាល់ខ្លួនដូចនេះដែរ៖ «ខ្ញុំមានសេចក្តីជាច្រើន នឹងសរសេរផ្ញើមកអ្នករាល់គ្នា តែមិនចង់សរសេរនៅក្រដាស ដោយទឹកខ្មៅនោះទេ ដ្បិតខ្ញុំសង្ឃឹមថា នឹងមកសួរអ្នករាល់គ្នា ហើយនិងនិយាយផ្ទាល់មាត់វិញ ដើម្បីឲ្យសេចក្តីអំណររបស់យើងរាល់គ្នា ចម្រើនបានពោរពេញឡើង» (២យ៉ូហាន ១:១២; ៣យ៉ូហាន ១:១៣-១៤)។

នៅក្នុងសង្គមឌីជីថលដែលមានពេញដោយការប្រេះស្រាំ និងភាពឯកោនេះ យើងពិតជាត្រូវការអំណាចនៃការមានវត្តមានយ៉ាងខ្លាំងក្នុងការស្តារចំណុចនេះឡើងវិញ។

## តើត្រូវមានវត្តមានបែបដូចម្តេច?

យើងទាំងអស់គ្នាដឹងថា វាអាចទៅរួចដែលថា យើងមានវត្តមាននៅទីនោះ ប៉ុន្តែអារម្មណ៍របស់យើងមិននៅទីនោះទេ។ ឪពុកអាចនៅផ្ទះបាន ប៉ុន្តែអារម្មណ៍មិននៅទីនោះទេ។ មិត្តភក្តិម្នាក់អាចស្តាប់ឮអ្វីដែលលោកអ្នកបានរៀបរាប់ ប៉ុន្តែមិនយល់អំពីដួងចិត្តរបស់លោកអ្នកទេ។ មានមនុស្សដែលយើងសង្ស័យថា ពួកគេមិនបង្ហាញខ្លួននៅក្នុងកម្មវិធីប្រជុំជប់លៀង ឬការជួបជុំគ្នាជាដើម ដោយសារវត្តមានរបស់ពួកគេមិនបានជួយអ្វីទេ។ ដូច្នេះ តើការមានវត្តមានបែបដូចម្តេចដែលយើងគួរមាននៅក្នុងក្រុមជំនុំ ក្រៅពីថា ឲ្យគ្រាន់តែមានវត្តមាននៅទីនោះ?

### *វត្តមានដែលមានភាពទៀតទាត់*

គ្រាប់ពូជមួយ មិនអាចដុះបានជាដើមឈើធំនៅថ្ងៃស្អែកនោះទេ។ វាអាចលូតលាស់បាន ដោយសារគេដាំវានៅក្នុងដីល្អ មានពន្លឺគ្រប់គ្រាន់ ហើយមានភ្លៀងធ្លាក់គ្រប់គ្រាន់។ គ្រីស្ទបរិស័ទក៏ដូចគ្នាដែរ។ យើងរីកចម្រើនបានដោយមានដីល្អនៃសហគមន៍ខាងឯវិញ្ញាណ មានសារធាតុចិញ្ចឹមដោយផ្អែកលើព្រះបន្ទូលរបស់ព្រះ និងបានកើតជាថ្មីដោយ

ព្រះវិញ្ញាណដែលគង់នៅក្នុងយើង។ ការជួបជុំគ្នានៅក្នុងដំណឹងល្អ មិនថានៅថ្ងៃអាទិត្យ ឬថ្ងៃផ្សេងទៀត គឺជារបៀបដ៏សំខាន់មួយដែលព្រះចម្រើនយើងឡើង។

ការភ្ជួរ ការសាបព្រួស ការស្រោចទឹក និងការដកស្មៅចេញ គឺមិនមែនជាសកម្មភាពមួយដ៏អស្ចារ្យនោះទេ។ ក្នុងរបៀបដូចគ្នាដែរ មិនថាការជួបជុំដែលមានគ្នាពេញបន្ទប់ទៀងទាត់ ឬការជួបជុំនៅយប់ណាមួយដែលនឿយហត់នោះទេ ក៏ការនោះមិនមានអ្វីពិសេសដែរ។ ប៉ុន្តែ សួនដែលមានដើមឈើពេញ និងគ្រីស្ទបរិស័ទដែលមានភាពចាស់ទុំ កើតមានឡើងតាមរយៈការធ្វើដដែលៗដែលមានពេញដោយប្រាជ្ញាដូចនេះ។

នៅក្នុងជីវិតជាគ្រីស្ទបរិស័ទ ការធ្វើវាដដែលៗគឺជារឿងសំខាន់ណាស់។ ការជួបប្រជុំគ្នាយ៉ាងទៀតទាត់ ការចែកចាយយ៉ាងទៀតទាត់ ការបង្រៀនយ៉ាងទៀងទាត់ ការស្តាប់យ៉ាងទៀងទាត់ ការអធិស្ឋានយ៉ាងទៀងទាត់ ការច្រៀងសរសើរតម្កើងយ៉ាងទៀងទាត់ ការបម្រើយ៉ាងទៀងទាត់—ទាំងនេះគឺជាអាវុធសម្ងាត់របស់យើងក្នុងការតយុទ្ធជាមួយអំពើបាបពោលគឺជាធាតុផ្សំនៅក្នុងរូបមន្តនៃភាពអំណររបស់គ្រីស្ទបរិស័ទ និងសារធាតុចិញ្ចឹមដែលបានចិញ្ចឹម

ថែរក្សាសុខភាពខាងឯព្រលឹងវិញ្ញាណរបស់យើង។ ភាពទៀងទាត់គឺជាអាវុធដ៏មានប្រសិទ្ធភាពមួយ ប៉ុន្តែវាជាអាវុធមិនសូវមានអ្នកមើលឃើញក្នុងការដើរជាមួយព្រះជាម្ចាស់ទេ។ ប្រៀបដូចជាគ្រាប់រុក្ខជាតិដែលកប់ក្នុងដីមួយដែរ ភាពទៀងទាត់មើលទៅមិនគួរឲ្យចាប់អារម្មណ៍ទេ ប៉ុន្តែត្រូវប្រើពេលរហូតដល់ថ្ងៃមួយដែលនឹងមកដល់។

## *ការមានវត្តមានដ៏ស្មោះត្រង់*

ភាពទៀតទាត់ មានន័យថាជាការបង្ហាញខ្លួនមិនថាយើងមានអារម្មណ៍បែបណានោះទេ។ ប៉ុន្តែ មានមនុស្សជាច្រើនមានការពិបាកក្នុងការទៅព្រះវិហារពីព្រោះពួកគាត់មានអារម្មណ៍ថា ពួកគាត់មិនមានភាពស្មោះត្រង់ចំពោះអ្វីដែលបានកើតឡើងនៅក្នុងជីវិតរបស់ពួកគាត់ទេ។ ពេលខ្លះ ពួកគាត់មិនជឿលើអ្នកណាទាំងអស់ថា អ្នកទាំងនោះមានភាពប្រាកដប្រជាជាមួយពួកគាត់។

ពេលខ្លះ មានអ្នកដទៃប្រាប់យើងឲ្យបំភ្លេចអំពីបញ្ហារបស់យើង ដើម្បីឲ្យយើងអាចផ្តោតលើក្រុមជំនុំបានល្អ ប៉ុន្តែតាមពិតទៅ ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យធ្វើផ្ទុយពីនេះ។ ព្រះយេស៊ូវមានព្រះ

បន្ទូលថា «អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សម្រាក» (ម៉ាថាយ ១១:២៨)។ ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យ «ផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា» (១ពេត្រុស ៥:៧)។ ស្តេចដាវីឌ បានអធិស្ឋានទៅកាន់ព្រះជាម្ចាស់ថា «ទ្រង់... ដាក់អស់ទាំងទឹកភ្នែករបស់ទូលបង្គំទុកនៅក្នុងដបនៃទ្រង់» (ទំនុកតម្កើង ៥៦:៨)។ កណ្ឌគម្ពីរទំនុកតម្កើងមានពេញទៅដោយអ្នកជឿដែលមានការនឿយហត់ស្រែកអំពាវនាវរកព្រះជាម្ចាស់ ទាំងនៅទីសាធារណៈសម្រាប់ជាការផ្គត់ផ្គង់ ការការពារ ការផ្តល់ដំណោះស្រាយ ការអត់ទោស កម្លាំង សេចក្តីសង្ឃឹម និងការសម្រាកជាដើម។ ក្រុមជំនុំដែលបានជួបប្រជុំគ្នាគួរតែមានលក្ខណៈដូចនេះដែរ។

របៀបដ៏ល្អបំផុតក្នុងការពង្រឹងភាពស្មោះត្រង់នៅក្នុងក្រុមជំនុំ គឺមិនមែនជាការចោលទោសគ្រប់គ្នាថា ពួកគេសម្តែងនោះទេ។ របៀបដ៏ល្អបំផុតក្នុងការពង្រឹងភាពស្មោះត្រង់ក្នុងក្រុមជំនុំ គឺភាពស្មោះត្រង់។ ជាញឹកញាប់ មនុស្សដំបូងគេណាដែលបានបើកចិត្តចែកចាយរឿងផ្ទាល់ខ្លួនចំពោះក្រុម គឺគាត់ជាម្នាក់ដែលបានផ្តើម ដើម្បីឲ្យអ្នកដទៃអាចចែក

ចាយអំពីរឿងផ្ទាល់ខ្លួនបន្ថែមទៀតបានដែរ។ ហេតុអ្វីបានជាមិនមានមនុស្សបែបនោះនៅក្នុងក្រុមជំនុំរបស់លោកអ្នក?

នេះមិនមែនមានន័យថា យើងបង្ហាញខ្លួនដោយការអាណិតខ្លួនឯង ឬខឹងសម្បារនោះទេ។ ការ «បើកចំហ» មិនគួរមានន័យថា ជាការនិយាយស្តីបន្ទោស ឡូឡា ស្រែកខ្លាំងៗ ឬបង្ករករឿងអ្នកដទៃ ដោយពាក្យពេចន៍ និងអាកប្បកិរិយាមិនស្រុះស្រួលគ្នានោះទេ។ ប៉ុន្តែ ការនេះមានន័យថា ជាការបង្ហាញខ្លួនយើងថាជាខ្លួនយើងយ៉ាងពិតប្រាកដនៅក្នុងព្រះវិហារ ហើយអនុញ្ញាតឲ្យព្រះគុណនៃការព្យាបាលរបស់ព្រះជាម្ចាស់លាងសម្អាតជីវិតខ្មៅខ្មាំរបស់យើង។

ជាទូទៅ មនុស្សមិនបានឆ្លើយតបដូចអ្វីដែលយើងចង់បាននោះទេ។ ពួកគេទំនងជានិយាយអំពីអ្វីមួយដែលមិនសមរម្យ អង្គុយនៅកន្លែងស្ងៀមស្ងាត់មិនប្រក្រតី ឬក៏និយាយមិនល្អពីយើងនៅពេលក្រោយផងដែរ។ ប៉ុន្តែ ដំណឹងល្អនៃព្រះគុណដោះលែងយើងឲ្យមានសេរីភាពក្នុងការដាក់ចុះនូវការលាក់បាំងរបស់យើង ហើយឲ្យយើងអាចឱបក្រសោបសេចក្តីសុចរិតរបស់ព្រះគ្រីស្ទដែលបានគ្របបាំងយើងយ៉ាងពេញលេញ (២កូរិនថូស ៥:២១)។

នៅពេលយើងជួបប្រជុំគ្នា វាប្រសើរជាងក្នុងការបង្ហាញទឹកមុខក្រៀមក្រំជាជាងបង្ហាញភាពសប្បាយតែពីខាងក្រៅ។ វាប្រសើរជាងក្នុងការបង្ហាញដួងចិត្តដែលខ្ទេចខ្ទាំជាជាងការមានពុតត្បុត។ យ៉ាងណាមិញ សេចក្ដីអធិស្ឋានជាសាធារណៈដ៏ល្អបំផុតមួយក្នុងចំណោមសេចក្ដីអធិស្ឋានជាច្រើននៅក្នុងព្រះគម្ពីរគឺបានមកពីការស្រែករកជំនួយខាងឯវិញ្ញាណ៖ «ឱព្រះអង្គអើយ សូមទ្រង់មេត្តាអត់ទោសដល់ទូលបង្គំ ដែលជាអ្នកមានបាបផង» (លូកា ១៨:១៣)។

### *ការមានវត្តមានដែលបន្ទាបខ្លួន*

នៅពេលយើងមានបញ្ហាក្នុងការទៅព្រះវិហារ វាក៏ជាការល្បួងមួយឲ្យយើងគិតអំពីខ្លួនឯងជាធំដែរ។ ភាពសោកសៅងាយឲ្យយើងអាណិតខ្លួនឯងណាស់។ ការចំអកឡកឡឺយអាចក្លាយទៅជាការរិះគន់យ៉ាងឆាប់រហ័ស។ ប្រភេទមិនត្រឹមត្រូវនៃ «ការមានវត្តមានដ៏ស្មោះត្រង់» អាចធ្វើឲ្យយើងមានលក្ខណៈផ្ទុយពីនោះវិញ ពោលគឺឥតគួរសម និងគ្មានចិត្តសប្បុរសជាដើម។

វាតែងតែងាយស្រួលក្នុងការបំផ្លិចបំផ្លាញជា

ជាងការសាងសង់ ប៉ុន្តែសំណួរគឺថា តើលោកអ្នកជាម្នាក់ដែលបំផ្លិចបំផ្លាញ ឬក៏ជាម្នាក់ដែលចូលចិត្តជួយឲ្យមានការរីកចម្រើនឡើង? លោកអ្នកអាចចំណាយកម្លាំងក្នុងការប្រើពាក្យសម្ដីរិះគន់អ្នកដទៃ ឬបម្រើអ្នកដទៃ ត្អូញត្អែរអំពីអ្នកដទៃ ឬលះបង់ខ្លួនឯងសម្រាប់អ្នកដទៃវិញ។ ប៉ុន្តែ វាជារឿងដែលពិបាកក្នុងការធ្វើបានទាំងពីរ។

ហោរា អេលីយ៉ា ធ្លាប់គិតថា គាត់គឺជាមនុស្សតែម្នាក់ដែលនៅតែស្មោះត្រង់ចំពោះព្រះជាម្ចាស់ ប៉ុន្តែព្រះអង្គបានរម្លឹកគាត់ថា នៅមានច្រើនជាងអ្វីដែលគាត់បានគិតទៅទៀត (១ពង្សាវតារក្សត្រ ១៩:៩-១៨)។ សាវ័ក ប៉ុល បានចំណាយពេលក្នុងវ័យយុវជនរបស់គាត់ ដើម្បីដោះស្រាយបញ្ហាធំៗនៅក្នុងក្រុមជំនុំដែលគាត់ស្រឡាញ់ ប៉ុន្តែគាត់ក៏តែងតែចង់ស្អាងគ្នាឡើងវិញ មិនមែនផ្ដួលនោះទេ (២កូរិនថូស ១៣:១០)។ ជាញឹកញាប់ ព្រះយេស៊ូវបានមានបន្ទូលបន្ទោសពួកសិស្សទាំង១២នាក់ ប៉ុន្តែព្រះអង្គគង់នៅជាមួយពួកគេ ហើយបម្រើពួកគេរហូតដល់ទីបញ្ចប់ សូម្បីតែ យូដាស-អ៊ីស្ការីយ៉ុត ដែលក្បត់ព្រះអង្គក៏ដោយ (យ៉ូហាន ១៣:១-១៥)។

មានហេតុផលត្រឹមត្រូវមួយចំនួនក្នុងការដែលយើងចាកចេញពីក្រុមជំនុំដូចជា នៅពេលក្រុមជំនុំ

បោះបង់ចោលដំណឹងល្អ មានទម្លាប់បដិសេធមិននិយាយពីអំពើបាប ឬនៅគាំទ្រអ្នកដឹកនាំអសីលធម៌ជាដើម។ ជារឿយៗ យើងចាត់ទុកគំនិតរបស់យើងទៅជាការជឿជាក់ ហើយចំណង់ចំណូលចិត្តរបស់យើងចង់ចងក្រងវាទៅជាគោលការណ៍។ យើងចាត់ទុកអ្វីៗដោយឈរលើគោលការណ៍ពីរគឺ ខុសនិងត្រូវដោយមិនបានទុកឲ្យមានចន្លោះនៅចំណុចកណ្ដាលនោះទេ (រ៉ូម ១៤:១-១៥:៧)។ ការជជែកវែកញែកអំពីបញ្ហាតូចតាចបានក្លាយជាបញ្ហាដ៏ធំ ហើយយើងចាប់ផ្ដើមផ្ដោតទៅលើរឿងដែលមិនសូវសំខាន់ជាជាងរឿងដែលសំខាន់ពិតប្រាកដ (ម៉ាថាយ ២៣:២៣-២៤)។

វាងាយស្រួលក្នុងការដែលយើងរិះគន់ក្រុមជំនុំរបស់ខ្លួន ហើយពេលខ្លះ ក៏មានការរិះគន់ជាច្រើនផងដែរ។ ប៉ុន្តែទោះជាយ៉ាងណាក្ដី វត្តមានដ៏ល្អបំផុតដែលយើងអាចធ្វើបាននៅក្នុងក្រុមជំនុំ គឺមិនមែនជា «វត្តមាននៃថ្កោលទោស ឬរិះគន់» នោះទេ ប៉ុន្តែជាវត្តមានដែលមានការបន្ទាបខ្លួន ពោលគឺចង់ស្ដាប់និងចេះស្រឡាញ់ ជាវត្តមានដែលបម្រើ ព្រមទាំងស្អាងគ្នាឡើងទៅវិញទៅមកផងដែរ។ នៅក្នុងព្រះគម្ពីរ យ៉ាកុប ៥:៩ បានចែងថា «បងប្អូនអើយ កុំឲ្យរទូរទាំទាស់នឹងគ្នាទៅវិញទៅមកឡើយ»។

### *វត្តមានដែលមានការរួបរួម*

មានដំណើររឿងមួយដែលបានដកស្រង់ចេញពីប្រជុំរឿងព្រេងអំពីសត្វគោបួនក្បាលរស់នៅតាមទីវាលមួយ។ ជាញឹកញាប់ មានសត្វតោមួយក្បាលតែងតែដើរក្រវែលសត្វគោទាំងនោះ ប៉ុន្តែនៅពេលណាដែលសត្វតោនោះចាប់ផ្ដើមចូលទៅវាយប្រហារ សត្វគោទាំងនោះក៏ឈរបែរខ្នងទល់គ្នាដោយមុខបែរចេញទៅទិសទាំងបួន ដូច្នេះនៅពេលសត្វតោនោះចូលមកពេលណា សត្វគោទាំងនោះអាចជល់បានតែម្ដង។ នៅថ្ងៃមួយ សត្វគោទាំងនោះក៏បានឈ្លោះប្រកែកគ្នា។ សត្វគោទាំងនោះខឹងគ្នាជាខ្លាំង ហើយក៏បានបែងចែកគ្នាទៅនៅជ្រុងម្ខាងៗនៃទីវាលរៀងៗខ្លួនទៅ។ បន្ទាប់មកសត្វតោក៏បានមកវាយប្រហារសត្វគោនោះស៊ីម្ដងមួយៗ ហើយសត្វតោនោះក៏បានស៊ីសត្វគោអស់យ៉ាងឆាប់រហ័ស។

ព្រះគម្ពីរមិនបានលាក់បាំងអំពីភាពពិតនៃជម្លោះនោះទេ។ លោក យ៉ាកុប និងលោក អេសាវ មានជម្លោះជាមួយគ្នា (លោកុប្បត្តិ ២៥:២៣) លោក អើរ៉ុន និងនាង ម៉ារាម មានទំនាស់ជាមួយលោក ម៉ូសេ (ជនគណនា ១២) ពួកសិស្សរបស់

ព្រះយេស៊ូវបានជជែកតវ៉ាទឹងគ្នា (ម៉ាកុស ៩:៣៤) សាវ័ក ប៉ុល និងលោក បាណាបាស បានបែកចេញពីគ្នា (កិច្ចការ ១៥:៣៩) នាង អើរ៉ូឌា និងនាង ស៊ុនទីច ឈប់ធ្វើការជាមួយគ្នា ហើយចាប់ផ្តើមមានទំនាស់ជាមួយគ្នា (ភីលីព ៤:២-៣)។

អំនួតល្បួងឲ្យយើងមិនឲ្យតម្លៃភាពស្រដៀងគ្នាដែលយើងមាន ហើយឲ្យយើងផ្តោតសំខាន់លើភាពខុសគ្នារបស់យើង។ យើងភ្លេចថា យើងមានភាពដូចគ្នាច្រើនជាងមានចំណុចខុសគ្នា ពោលគឺមានអ្វីដែលដូចគ្នាច្រើនជាងអ្វីដែលញែកយើងដាច់ចេញពីគ្នា។ ដូច្នេះ សាវ័ក ប៉ុល លើកទឹកចិត្តឲ្យគ្រីស្ទបរិស័ទ «ឲ្យមូលគំនិតតែ១ក្នុងព្រះអម្ចាស់» (ភីលីព ៤:២)។ សាវ័ក ប៉ុល បានបន្តថា ការមានជម្លោះនៅក្នុងក្រុមជំនុំធ្វើឲ្យគាត់សោកសង្រេងក្នុងចិត្តយ៉ាងខ្លាំង ប៉ុន្តែការរួបរួមគ្នាដ៏ពិតបញ្ចេះសេចក្តីអំណររបស់គាត់ឡើងវិញ៖ «ចូរបំពេញសេចក្តីអំណររបស់ខ្ញុំ ដោយអ្នករាល់គ្នាមានគំនិត មានសេចក្តីស្រឡាញ់តែ១ ទាំងរួបរួមចិត្តគ្នា ហើយគិតតែផ្លូវ១ដូចគ្នាចុះ» (ភីលីព ២:២)។

យើងគួរតែអធិស្ឋាន មានការប្រព្រឹត្ត និងមានការលះបង់ ដើម្បីឲ្យមានការរួបរួម។ នៅក្នុងព្រះគម្ពីរ ម៉ាថាយ ៥:៩ មានចែងថា «មានពរហើយ អស់អ្នក

ដែលផ្សះផ្សាគេ ដ្បិតអ្នកទាំងនោះនឹងបានហៅជាកូនរបស់ព្រះ»។ ព្រះបានត្រាស់ហៅយើងឲ្យមានការរីកចម្រើនឡើង៖

> «ដូច្នេះ ចូរប្រដាប់កាយ ដោយចិត្តក្តួលអាណិត សប្បុរស សុភាព សំឡូត និងចិត្តអត់ធ្មត់ ទុកដូចជាពួកអ្នករើសតាំង ដែលបរិសុទ្ធ ហើយស្ងួនភ្ងាដល់ព្រះចុះ ហើយទ្រាំទ្រគ្នា ទាំងអត់ទោសទៅវិញទៅមក បើអ្នកណាមានហេតុទាស់នឹងអ្នកណា នោះចូរអត់ទោសឲ្យគេចុះ ដូចជាព្រះគ្រីស្ទបានអត់ទោសឲ្យអ្នករាល់គ្នាដែរ ចូរបន្ថែមទាំងសេចក្តីស្រឡាញ់ថែមទៀត ជាចំណងនៃសេចក្តីគ្រប់លក្ខណ៍ ចូរឲ្យសេចក្តីមេត្រីរបស់ព្រះគ្រីស្ទត្រួតត្រានៅក្នុងចិត្ត ដែលទ្រង់បានហៅអ្នករាល់គ្នាមកក្នុងសេចក្តីនោះឯង ឲ្យមានរូបកាយតែ១ ហើយត្រូវដឹងគុណផង» (កូឡូស ៣:១២-១៤)។

គ្រីស្ទបរិស័ទដែលរីកចម្រើនត្រូវរៀនមើលអំពីទស្សនៈនៃការជំទាស់គ្នាតូចៗជាច្រើនដូចជាអ្វីដែលសាវ័ក ប៉ុល បានធ្វើដែរ៖ «ដូច្នេះ យើងទាំងអស់គ្នាដែលគ្រប់លក្ខណ៍ហើយ យើងត្រូវមានគំនិតយ៉ាងនោះឯង តែបើអ្នករាល់គ្នាមានគំនិតណាផ្សេងក្នុង

ការអ្វី នោះព្រះទ្រង់នឹងសម្តែងឲ្យអ្នករាល់គ្នាបាន ឃើញសេចក្តីនេះដែរ» (ភីលីព ៣:១៥)។

## *វត្តមានដែលមានការយល់ដឹង*

ការបន្ទាបខ្លួន និងការរួបរួមមិនមែនមានន័យថា យើងខ្វាក់ដោយទទួលយកអ្វីៗគ្រប់យ៉ាង ឬមិន ខ្វល់ខ្វាយជាមួយគំនិតដែលមានប្រាជ្ញានោះទេ៖ «មនុស្សឆោតល្ងង់គេជឿគ្រប់ពាក្យទាំងអស់ តែ មនុស្សមានគំនិតវាងវៃរមែងមើលផ្លូវខ្លួនដោយ ប្រយ័ត្ន» (សុភាសិត ១៤:១៥)។ ជាការពិតណាស់ យើងមិនគួរធ្វើជាអ្នករិះគន់ឥតឈប់ឈរនោះទេ (សុភាសិត ២៧:១៥) ប៉ុន្តែយើងក៏មិនគួរធ្វើដូចជា ចៀមឆោតល្ងង់ដែលមិនអាចបែងចែកបានរវាង ស្មៅសិប្បនិមិត្ត និងស្មៅធម្មជាតិ ឬមួយណាជា ចចក និងមួយណាជាអ្នកគង្វាលបានដែរ (កិច្ចការ ២០:២៨-៣០)។ ព្រះគុណមិនគួរធ្វើឲ្យយើងងាយ ចាញ់បញ្ឆោតគេឡើយ។

ពួកសាសន៍យូដានៅក្នុងក្រុងបេរា «គេប្រុង ប្រៀបសព្វគ្រប់នឹងទទួលព្រះបន្ទូល ក៏ពិចារណា មើលគម្ពីររាល់តែថ្ងៃ ឲ្យបានដឹងជាសេចក្តីទាំងនោះ ត្រូវឬមិនត្រូវ» (កិច្ចការ ១៧:១១)។ គ្រីស្ទបរិស័ទ

ដែលមានភាពចាស់ទុំមានការយល់ថា «ឯអាហាររឹង នោះសម្រាប់តែមនុស្សធំ ដែលបានបង្ហាត់ឥន្ទ្រីយ៍ដោយធ្លាប់ខ្លួនហើយ ដើម្បីឲ្យបានដឹងខុសត្រូវ» (ហេព្រើរ ៥:១៤)។ គ្រីស្ទបរិស័ទដែលស្មោះត្រង់តែងតែនិយាយប្រាប់ ហើយជួយគ្នាទៅវិញទៅមកឲ្យបានដើរលើផ្លូវត្រូវ (សុភាសិត ២៧:៦)។

សាវ័ក ប៉ុល បានបន្ទោសដល់លោក ពេត្រុស នៅពេលដែលលោក ពេត្រុស បានធ្វើឲ្យខូចដល់ដំណឹងល្អនៃព្រះគុណដោយបានអនុវត្តតាមខ្នាតតម្រាច្បាប់ទៅលើគ្រីស្ទបរិស័ទផ្សេងទៀត (កាឡាទី ២:១១-២១)។ សាវ័ក ប៉ុល ក៏បានប្រាប់ដល់ ធីម៉ូថេ ឲ្យដោះស្រាយកំហឹង ភាពមិនសមរម្យ និងបញ្ហាបញ្ហាទាក់ទងនឹងភេទនៅក្នុងក្រុមជំនុំ (១ធីម៉ូថេ ២:៨-១៥)។ សាវ័ក យ៉ាកុប បានព្រមានដល់ក្រុមជំនុំទាំងអស់ដែលបានទទួលអ្នកមាន និងអ្នកក្រដែលបានចូលមកខុសៗគ្នា (យ៉ាកុប ២:១-៧)។ សាវ័ក ប៉ុល ក៏ថែមទាំងព្រមានដល់អ្នកនៅក្រុងកាឡាទីឲ្យប្រឆាំងទាស់នឹងភាពប្លែកពីគ្នារបស់គាត់នាពេលអនាគត ប្រសិនបើគាត់អធិប្បាយអ្វីផ្សេងខុសពីដំណឹងល្អ នោះចូរឲ្យពួកគេបដិសេធគាត់ចុះ (កាឡាទី ១:៨)។ គ្រីស្ទបរិស័ទគ្រប់រូបត្រូវតែត្រៀមខ្លួនឲ្យបានរួចរាល់ក្នុងការវែកញែកឲ្យបានដឹងរវាង

ខុស និងត្រូវ ការមានប្រាជ្ញា និងភាពល្ងង់ខ្លៅ ព្រម ទាំងអ្វីដែលស្របតាមព្រះគម្ពីរ និងអ្វីដែលមិនស្រប តាមព្រះគម្ពីរ។

ប្រសិនបើលោកអ្នកកំពុងមានបញ្ហានៅក្នុង ក្រុមជំនុំរបស់លោកអ្នក ភារកិច្ចរបស់លោកអ្នកគឺ មិនត្រូវនិយាយបំផ្លើស ឬកាត់បន្ថយបញ្ហាចោល នោះទេ។ ផ្ទុយទៅវិញ សូមគិតពិចារណាអំពីដំណើរ ការខាងក្រោមនេះ៖

១) សូមសិក្សាពីបទគម្ពីរ (ទំនុកតម្កើង ១:២)។
២) អធិស្ឋានទូលសូមប្រាជ្ញា (យ៉ាកុប ១:៥)។
៣) ត្រូវគិតពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយ (សុភាសិត ១៨:១៧)។
៤) សូមថ្លឹងថ្លែងអំពីបញ្ហានោះ (សុភាសិត ១៧:១៣)។
៥) ពិនិត្យមើលខ្លួនលោកអ្នកផ្ទាល់ (ម៉ាថាយ ៧:៣-៥)។
៦) រកអ្នកប្រឹក្សាយោបល់ដែលមានប្រាជ្ញា (សុភាសិត ១១:១៤)។
៧) អធិស្ឋានសម្រាប់អស់អ្នកដែលមានចំណែក ចូលរួមក្នុងបញ្ហានោះ (រ៉ូម ១២:១២)។
៨) ចូរកំណត់អំពីទំនួលខុសត្រូវរបស់លោកអ្នក

(សុភាសិត ២៦:១៧)។

៩) ចូររៀបចំខ្លួនជាមុនឲ្យមានភាពអត់ធ្មត់ (១ថែស្សាឡូនីច ៥:១៤)។

១០) ចូរប្រព្រឹត្តដោយសេចក្ដីជំនឿ (សុភាសិត ៣:៥-៦)។

១១) ចូរនិយាយដោយចិត្តសុភាព (២ធីម៉ូថេ ២:២៥)។

១២) ចូរចំណាយពេលវេលារង់ចាំ (១កូរិនថូស ១៣:៤)។

១៣) ចូរសង្ឃឹមសម្រាប់អ្វីដែលល្អបំផុត (១កូរិនថូស ១៣:៧)។

ជាមួយគ្នានេះដែរ សូមចងចាំថា គ្រប់ក្រុមជំនុំទាំងអស់ក៏មានបញ្ហាដែរ ដោយសារតែក្រុមជំនុំនីមួយៗមានមនុស្សចូលរួមដូចគ្នា។ ព្រះយេស៊ូវមិនបានសុគតសម្រាប់ពួកបរិសុទ្ធនោះទេ ប៉ុន្តែទ្រង់បានសុគតសម្រាប់មនុស្សមានបាបវិញ។ បន្ទាប់មកព្រះអង្គបានចាត់ព្រះវិញ្ញាណរបស់ទ្រង់មកសណ្ឋិតលើមនុស្សមានបាបទាំងនោះ ដើម្បីឲ្យបានបរិសុទ្ធបន្តិចម្ដងៗនៅក្នុងជីវិតរបស់ពួកគេ។ ដូច្នេះ នៅក្នុងស្ថានភាពភាគច្រើន នៅពេលដែលយើងយល់ដឹងអំពីបញ្ហានៅក្នុងក្រុមជំនុំរបស់យើង របៀបដែល

យើងឆ្លើយតបគួរតែដូចគ្នាទៅនឹងការឆ្លើយតបចំពោះអ្នកជំងឺ ឬអ្នកមានរបួសទូទៅផងដែរ៖ ការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវ ការព្យាបាលត្រឹមត្រូវ ហើយអ្នកជំងឺក៏ត្រូវមានវិន័យត្រឹមត្រូវ ដើម្បីទទួលបានការព្យាបាលដ៏ត្រឹមត្រូវផងដែរ។ វាមិនមែនជាជម្រើសដ៏ល្អទី១នោះទេ ក្នុងការកាត់ផ្នែកណាមួយនៃរាងកាយរបស់យើងចេញភ្លាមៗ ហើយតម្រូវឲ្យមានការផ្លាស់ប្តូរសរីរាង្គនោះ។

### *វត្តមានដែលសកម្ម*

ដូចគ្នាទៅនឹងការមានរបៀបពីរយ៉ាងក្នុងការដង្ហែក្បួន—គឺការចូលដើរជាក្បួន ឬការគ្រាន់តែឈរសម្លឹងមើល នោះក៏មានរបៀបពីរយ៉ាងក្នុងការចូលរួមក្នុងក្រុមជំនុំដែរ គឺជា—ចូលរួមយ៉ាងសកម្ម ឬអសកម្ម។ អ្នកអាចជាម្នាក់ដែលប្រើប្រាស់ ឬក៏ជាម្នាក់ដែលមានចំណែកជួយ ពោលគឺគ្រាន់ជាអ្នកចាំមើល ឬអ្នកដែលចូលទៅបម្រើ។ ប៉ុន្តែ ប្រសិនបើលោកអ្នកចង់បានភាពសប្បាយរីករាយនៅក្នុងព្រះវិហារ នោះចូលធ្វើជាអ្នកមានចំណែកជួយចុះ។ យើងអាចស្វែងយល់អំពីអាថ៌កំបាំងអំពីសេចក្តីអំណរដែលមានលក្ខណៈដូចទៅនឹងព្រះគ្រីស្ទ

បានគឺថា៖ «ដែលឲ្យ នោះបានពរជាជាងទទួល» (កិច្ចការ ២០:៣៥)។

ដំណឹងល្អគឺជាដំណឹងដ៏អស្ចារ្យ ដោយសារព្រះគ្រីស្ទគឺជាអំណោយដ៏អស្ចារ្យដល់យើង (រ៉ូម ៨:៣២)។ ប៉ុន្តែ ព្រះជាម្ចាស់មិនគ្រាន់តែឲ្យយើងទទួលបាននូវព្រះទ័យសប្បុរសរបស់ទ្រង់ប៉ុណ្ណោះទេ៖ ទ្រង់បានឲ្យយើងដែលជាអ្នកទទួលពីទ្រង់រស់នៅដោយបង្ហាញអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គជាសេចក្តីស្រឡាញ់ដែល «បានផ្សាយមកសព្វក្នុងចិត្តយើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធដែលព្រះបានប្រទានមកយើងហើយ» (រ៉ូម ៥:៥)។ សេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទចំពោះយើង បានក្លាយជាសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទដែលនៅក្នុងយើង ហើយសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទដែលនៅក្នុងយើងនោះ ក៏បានក្លាយជាសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទដែលបានបង្ហាញតាមរយៈយើង។ នៅក្នុងព្រះគម្ពីរ យ៉ូហាន ១៣:៣៤ បានចែងថា «គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ»។

តើសេចក្តីស្រឡាញ់ដែលសកម្មនោះមានលក្ខណៈយ៉ាងដូចម្តេច? គឺនៅក្នុងការ*កំឡាចិត្តគ្នា*

*ទៅវិញទៅមក*។

អ្នកចាំមើលមានទំនោរទៅរករបៀបបីយ៉ាង៖ មានអំណរ វាយតម្លៃ និងរិះគន់។ ប៉ុន្តែ នៅក្នុងព្រះគម្ពីរហេព្រើរ នៅពេលដែលព្រះជាម្ចាស់បានរម្លឹកដល់ក្រុមគ្រីស្ទបរិស័ទដែលទទួលរងការបៀតបៀនឲ្យមានការប្រជុំគ្នាយ៉ាងទៀងទាត់ ទ្រង់បានបង្គាប់ប្រាប់គេយ៉ាងច្បាស់ថា ត្រូវឲ្យកំឡាចិត្តគ្នាទៅវិញទៅមកនៅក្នុងសេចក្ដីជំនឿ។

> «ហើយត្រូវឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្ដាលឲ្យមានសេចក្ដីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំឡាចិត្តគ្នាវិញ ឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ» (ហេព្រើរ ១០:២៤-២៥)។

សូមកត់សម្គាល់អំពីភាពផ្ទុយគ្នានៃពាក្យ*លែងប្រជុំគ្នា* គឺមិនមែនសំដៅទៅលើការ*ចូលរួម*នោះទេ។ អ្នកនិពន្ធកណ្ឌគម្ពីរនេះមិនបានគ្រាន់តែប្រាប់យើងឲ្យមកព្រះវិហារជាជាងគ្រាន់តែនៅផ្ទះនោះឡើយ ប៉ុន្តែគាត់បានប្រាប់យើងឲ្យកំឡាចិត្តគ្នាទៅវិញទៅមកជំនួសឲ្យការឥតលែងប្រជុំគ្នាវិញ។ ការចូល

រួមគឺជាការរំពឹងទុកឲ្យកើតមានឡើងក្នុងក្រុមជំនុំ ហើយតួនាទីរបស់យើងក្នុងការចូលរួមគឺត្រូវកំឡាចិត្តគ្នាទៅវិញទៅមក។

ទាំងទាហាននៅក្នុងសមរភូមិ អត្តពលិកនៅពហុកីឡាដ្ឋាន មេចុងភៅនៅផ្ទះបាយ និងគ្រីស្ទបរិស័ទនៅក្នុងព្រះវិហារ—ពួកគាត់ទាំងអស់សុទ្ធតែនៅកន្លែងដែលពួកគាត់ត្រូវនៅ។ ប៉ុន្តែ វត្តមានតែម៉្យាងមិនមែនជាគោលដៅចុងក្រោយនោះទេ។ ទាហានគួរតែប្រយុទ្ធ អត្តពលិកគួរតែប្រកួតប្រជែង មេចុងភៅគួរតែចម្អិនម្ហូបអាហារ ហើយគ្រីស្ទបរិស័ទក៏គួរតែកំឡាចិត្តគ្នាទៅវិញទៅមកនៅក្នុងគ្រួសារខាងព្រលឹងវិញ្ញាណរបស់គាត់ដែរ។

ការកំឡាចិត្តគ្នានេះមានលក្ខណៈខុសៗគ្នាអាស្រ័យទៅតាមមនុស្សម្នាក់ៗ។ ព្រះបានត្រាស់ហៅយើងឲ្យ «កាន់តាមសេចក្តីពិតដោយសេចក្តីស្រឡាញ់វិញ» (អេភេសូរ ៤:១៥-១៦)។ ប៉ុន្តែគ្រីស្ទបរិស័ទម្នាក់ៗក៏ត្រូវមានឧបករណ៍ពិសេសខាងវិញ្ញាណដែរ ពោលគឺជា «អំណោយទាន» ដើម្បីនឹងស្អាងបងប្អូនរួមជំនឿឡើង (រ៉ូម ១២:៣-៨)។

គ្រីស្ទបរិស័ទមួយចំនួនប្រព្រឹត្តដោយល្អប្រសើរជាងគ្រីស្ទបរិស័ទផ្សេងដោយគិតថា អំណោយទានរបស់ពួកគាត់សំខាន់ជាងគេ។ ប៉ុន្តែ គ្រីស្ទបរិស័ទ

មួយចំនួនទៀតប្រព្រឹត្តតិចជាងនោះដោយគិតថា អំណោយទានរបស់ពួកគាត់មិនសូវសំខាន់ទេ។ ប៉ុន្តែ សាវ័ក ប៉ុល បានដាស់តឿនយើងកុំឲ្យយកការនោះធ្វើជារូបព្រះ ឬដកផ្នែកណាមួយនៃរូបកាយចេញចោលទេ ពីព្រោះទាំងជើង ដៃ ត្រចៀក និងភ្នែក ទាំងអស់មានតួនាទីយ៉ាងសំខាន់ (១កូរិនថូស ១២:១២-២៦)។ វាជាការល្អដែល «អវយវៈទាំងនោះមានការងារផ្សេងៗ» (រ៉ូម ១២:៤)។

តើលោកអ្នកអាចស្គាល់អំពីអំណោយទានរបស់លោកអ្នកដោយរបៀបណា ដើម្បីឲ្យលោកអ្នកបានប្រើអំណោយទានទាំងនោះបម្រើនៅក្នុងក្រុមជំនុំរបស់ខ្លួនបាន? សូមសម្លឹងរកអ្វីដែលក្រុមជំនុំត្រូវការ ចាប់ផ្ដើមបម្រើ ស្វែងយល់អំពីអ្វីដែលលោកអ្នករីករាយក្នុងការបម្រើ ស្ដាប់មតិយោបល់កែលម្អព្រមទាំងនៅតែបន្តផ្ដោតទៅលើសេចក្ដីស្រឡាញ់ផងដែរ។ ចូរចាក់បង្ហូរកម្លាំងរបស់លោកអ្នកដោយការបម្រើអ្នកដទៃ ដូចជាអ្នកបានបង្ហូរសេចក្ដីស្រឡាញ់ទៅក្នុងជីឡាវដែលកំពុងត្រងដែរ។ ព្រះជាម្ចាស់នឹងបង្ហាញឲ្យវិញ្ញាណដែលស្ម័គ្របម្រើនោះ ដើរតាមផ្លូវមួយដ៏ត្រឹមត្រូវ។

## *វត្តមានដែលមិនល្អឥតខ្ចោះ*

នៅពេលលោកអ្នកនៅក្នុងក្រុមជំនុំមួយបានយូរគួរសម នោះលោកអ្នកប្រាកដជាមានការខកចិត្តពីអ្នកដទៃ ហើយអ្នកដទៃក៏ខកចិត្តដោយសារលោកអ្នកដែរ។ លោកអ្នកមានបទពិសោធន៍នៃការមានជម្លោះ ការបែកបាក់ និយាយដើមគ្នា គិតថាខ្លួនអន់ជាងគេ កំហឹង ការព្រងើយកន្តើយ ពោលគឺរឿងគ្រប់យ៉ាងដែលនាំឲ្យមនុស្សជាតិបានបរាជ័យ។ លោកអ្នកនឹងឃើញរឿងទាំងនេះកើតឡើងចំពោះទាំងមនុស្សវ័យក្មេង និងមនុស្សចំណាស់ អ្នកដឹកនាំ និងអ្នកដើរតាម សមាជិកក្រុមជំនុំយូរឆ្នាំ ក៏ដូចជាអ្នកទើបតែជឿថ្មីផងដែរ។ ប្រសិនបើលោកអ្នកបន្ទាបខ្លួន នោះលោកអ្នកនឹងឃើញការទាំងនោះ ជាពិសេសនៅក្នុងខ្លួនលោកអ្នកផ្ទាល់៖ «ពិតប្រាកដជាគ្មានមនុស្សសុចរិតណានៅផែនដីដែលប្រព្រឹត្តសុទ្ធតែល្អឥតធ្វើបាបឡើយនោះទេ» (សាស្តា ៧:២០)។

ការបាក់បែកនេះគ្មានអ្វីថ្មីទេ។ ស្តេច ដាវីឌ បានប្រព្រឹត្តិការកំផិត និងបានសម្លាប់មនុស្ស (២សាំយូអែល ១១)។ លោក យ៉ាកុប និង លោក យ៉ូហាន បានលើកតម្កើងខ្លួនឯង (ម៉ាកុស

១០:៣៧)។ លោក ពេត្រុស បានបដិសេធមិនស្គាល់ព្រះយេស៊ូវ (ម៉ាថាយ ២៦:៦៩-៧៥)។ សូម្បីតែលោក បាណាបាស ដែលគេស្គាល់ថា ជាអ្នកដែលមានវិញ្ញាណស្វាគមន៍ក៏ត្រូវបណ្ដោយតាមអំពើកំពុតរបស់គ្រីស្ទបរិស័ទផ្សេងទៀតដែរ (កាឡាទី ២:១១-១៤)។ ក្រុមជំនុំដែលមានការជួបជុំគ្នាមិនមែនជាកន្លែងដែលមានទុកដាក់គំរូដើមដ៏ល្អឥតខ្ចោះនោះទេ ប៉ុន្តែជាកន្លែងដុសខាត់មនុស្សមានបាបដែលបានទទួលសេចក្ដីសង្គ្រោះរួចហើយឲ្យបានប្រសើរឡើង។

ទោះជាយ៉ាងណាក្ដី ភាពខ្វះខាតរបស់យើងនៅក្នុងគ្រួសាររបស់ព្រះមិនមែនជាហេតុផលក្នុងការដែលយើងជ្រើសរើសយកការផ្ដាច់ទំនាក់ទំនងជាជាងការប្រកបគ្នានោះទេ។ ជាជាងការនៅដាច់ឆ្ងាយពីគ្នា យើងគួរតែឆ្លើយតបដោយភាពឧស្សាហ៍ព្យាយាមវិញ៖ «យើងខ្ញុំទូន្មានឲ្យអ្នករាល់គ្នាបន្ទោស ដល់ពួកអ្នកដែលគ្មានសណ្ដាប់ធ្នាប់ ហើយជួយកម្សាន្តដល់ពួកអ្នកណាដែលមានសេចក្ដីទន់ក្រំចិត្ត ទាំងគាំពារពួកអ្នកដែលខ្សោយ និងអត់ឱនចំពោះមនុស្សទាំងអស់» (១ថែស្សាឡូនីច ៥:១៤)។ សូមកុំឈប់បង្ហាញខ្លួនដោយសារក្រុមជំនុំរបស់លោកអ្នកមានកំហុស ឬដោយសារលោក

អ្នកមានកំហុសខ្លួនឯងឡើយ។ ផ្ទុយទៅវិញ សូមបង្ហាញខ្លួន ព្រមទាំងមានភាពអត់ធ្មត់ក្នុងការចូលរួមក្នុងដំណើរការស្តារឡើងវិញពេញមួយជីវិតផងដែរ។ ព្រះជាម្ចាស់មានបន្ទូលសន្យាដល់គ្រប់គ្រីស្ទបរិស័ទ និងគ្រប់ក្រុមជំនុំថា «ព្រះអង្គដែលទ្រង់បានចាប់តាំងធ្វើការល្អក្នុងអ្នករាល់គ្នា ទ្រង់នឹងធ្វើឲ្យកាន់តែពេញខ្នាតឡើង» (ភីលីព ១:៦)។

### *វត្តមានដែលមានការអត់ទោស*

មិនយូរប៉ុន្មានក្រោយពេលខ្ញុំក្លាយជាគ្រូគង្វាល សមាជិកនៅក្នុងក្រុមជំនុំដ៏យូរឆ្នាំម្នាក់បានណាត់ដើម្បីជួបគ្នាជាមួយខ្ញុំ។ សមាជិកម្នាក់នេះចង់ប្រាប់ខ្ញុំពីគ្រប់រឿងទាំងអស់ទាក់ទងជាមួយនឹងក្រុមជំនុំរបស់យើង។ ប៉ុន្តែ អ្វីដែលគាត់បាននិយាយចេញមកគឺសុទ្ធតែជាការស្រងាកចិត្ត។ ក្រោយមកនៅយប់នោះ ខ្ញុំបានសរសេរគ្រប់ការត្អូញត្អែរទាំងអស់ដែលខ្ញុំបានចាំនៅពេលយើងនិយាយគ្នាជាមួយគាត់អស់រយៈពេលពីរម៉ោងនោះ។ មានការឈឺចាប់ចំនួនពាពដង ដែលបុរសម្នាក់នេះបានលើកឡើងនៅពេលដែលគាត់នៅក្រុមជំនុំរាប់ឆ្នាំមកនេះ។ បន្ទាប់ពីអស់រយៈពេលជាច្រើនឆ្នាំមក

នេះ គ្រីស្ទបរិស័ទម្នាក់នេះមិនអាចទ្រាំទ្របានទៀតទេ ដោយសារគាត់បានជ្រើសរើសយកការគុំគួនជាជាងជ្រើសយកព្រះគុណរបស់ព្រះ។

ការមិនអត់ទោសឲ្យគ្នាគឺជាផ្លូវទៅរកការអន់ចិត្តនឹងគ្នា។ ប៉ុន្តែ ព្រះយេស៊ូវបង្រៀនយើងអំពីរបៀបមួយដែលប្រសើរជាងនេះ៖ នៅពេលព្រះជាម្ចាស់អត់ទោសឲ្យយើង ហើយយើងចេះអត់ទោសឲ្យអ្នកដទៃ នោះទើបយើងអាចរីកចម្រើនបាន។ យើងមិនគួរភ្ញាក់ផ្អើលទេ នៅពេលដែលព្រះយេស៊ូវបានបង្រៀនយើងឲ្យអធិស្ឋានថា «សូមអត់ទោសសេចក្ដីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោសដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ» (ម៉ាថាយ ៦:១២)។ សាវ័ក ប៉ុល បានសរសេរថា «ចូរខំដកគ្រប់ទាំងសេចក្ដីជូរល្វីង ក្តៅក្រហាយ កំហឹង ឡូឡាជេរប្រមាថ និងគ្រប់ទាំងសេចក្ដីអាក្រក់ ចេញពីពួកអ្នករាល់គ្នាទៅ ចូរមានចិត្តសប្បុរសនឹងគ្នាទៅវិញទៅមក ព្រមទាំងមានចិត្តទន់សន្ដោស ហើយអត់ទោសគ្នា ដូចជាព្រះទ្រង់បានអត់ទោសឲ្យអ្នករាល់គ្នា ដោយព្រះគ្រីស្ទដែរ (អេភេសូរ ៤:៣១-៣២)។ គ្មានអ្វីដែលនឹងឃាត់យើងមិនឲ្យទៅព្រះវិហារជាជាងការដែលមានចិត្តទាមទារ និងចិត្តដែលមិនអត់ទោសនោះទេ។ ហើយក៏គ្មានអ្វីដែលអាចជួយពង្រឹង

លោកអ្នកក្នុងការជួបជាមួយគ្រួសារនៃក្រុមជំនុំរបស់ខ្លួនដូចជាទំនាក់ទំនងដែលស៊ីជម្រៅ រីករាយ មានមេត្រីភាព ព្រមទាំងបានផ្សះផ្សាដូចជាការកម្សាន្តចិត្ត និងការលើកទឹកចិត្តនោះដែរ។

## *វត្តមានដែលបានត្រៀមខ្លួនហើយជាស្រេច*

កាលកូនៗរបស់ខ្ញុំនៅតូចនៅឡើយ ខ្ញុំបានបង្វឹកដល់ក្រុមកីឡារបស់ពួកគេមួយចំនួន។ មុនពេលហាត់សម ឬមុនពេលលេង ក្មេងៗមិនចង់ពត់ដៃពត់ជើងឡើយ។ ពួកគេចង់លេងតែម្តង។ ប៉ុន្តែ នៅពេលខ្ញុំលេងជាមួយក្មេងជំទង់ ឬមនុស្សធំ យើងទាំងអស់គ្នាសុទ្ធតែពត់ដៃពត់ជើងមុនការប្រកួត។ យើងដឹងថា រាងកាយរបស់យើងត្រូវការឲ្យយើងធ្វើបែបនេះ។

នៅក្នុងជីវិតគ្រីស្ទជាបរិស័ទ មានពេលពេលវេលាតិចតួចដែរដែលយើងត្រូវការពត់ដៃពត់ជើងបែបដូចគ្នានេះ។ យើងមានអារម្មណ៍ថា តិចតួចហើយមានភាពស្វាហាប់ តែងតែត្រៀមខ្លួនហើយជាស្រេច ដើម្បីនិយាយ ផ្តល់ឲ្យ ចែករំលែក បម្រើ និងទទួលស្វាគមន៍អ្នកដទៃ។ ព្រលឹងរបស់យើងទន់ភ្លន់ រហ័សរហួន និងត្រៀមហើយជាស្រេច។

យើងប្រៀបដូចជាក្មេងៗរត់លេងដោយមិនចាំបាច់ពត់ដៃពត់ជើងអញ្ចឹង។

ប៉ុន្តែ ជីវិតជាគ្រីស្ទបរិស័ទ ទោះបីជាមានអំណរក៏នោះមិនមែនជាកន្លែងលេងដែរ។ តាមពិត វាជាសមរភូមិវិញទេតើ។ ព្រលឹងរបស់យើងឃ្លាតឆ្ងាយពីព្រះ (មានភាពត្រជាក់) មានបញ្ហានៅក្នុងទំនាក់ទំនង (ដួងចិត្តប្រេះស្រាំ) ហើយគំនិតរបស់យើងរវល់ជាមួយលោកីយ៍ (គំនិតដែលរំខានយើង)។ ទំនាក់ទំនងមួយចំនួនមានភាពរឹងមាំ ប៉ុន្តែមួយចំនួនទៀតក៏បែកបាក់ និងរសាត់បាត់ពីគ្នា។ មានពេលដែលយើងមានការជំរុញចិត្តយ៉ាងខ្លាំង ហើយក៏មានពេលខ្លះទៀតដែលយើងបាក់ទឹកចិត្ត និងមិនមានអារម្មណ៍ចង់ធ្វើអ្វីផងដែរ។ តាមរយៈការប៉ះទង្គិច និងស្នាមជាំទាំងអស់ តាមរយៈការឡើង និងការធ្លាក់ចុះនៅក្នុងជីវិតរបស់យើង នោះយើងអាចភ្លេចរសជាតិព្រះគុណរបស់ព្រះ ហើយយើងក៏ងាយនឹងមើលមិនឃើញអំពីបំណងព្រះទ័យរបស់ទ្រង់ផងដែរ។

នៅក្នុងពេលវេលាទាំងនេះ ក្រុមជំនុំអាចក្លាយជាបន្ទុកជាជាងព្រះពរសម្រាប់យើង។ ប៉ុន្តែ ដោយមានព្រះបន្ទូលដឹកនាំយើង ព្រះវិញ្ញាណជួយយើង ហើយបងប្អូនរួមជំនឿលើកទឹកចិត្តយើង នោះយើងអាចស្វែងរកឃើញព្រះគុណដ៏កក់ក្តៅឡើងវិញ និង

ព្រះគុណនៃការចិញ្ចឹមបីបាច់ថែរក្សាចេញពីការជួបជុំគ្នានៅក្នុងក្រុមជំនុំផងដែរ។ សូម្បីតែមុនពេលយើងមកដល់ចំណុចនេះក៏ដោយ ក៏យើងអាចអនុវត្តជំហានសាមញ្ញមួយចំនួន ដើម្បីឲ្យយើងអាចក្លាយជាអ្នកចូលរួមដ៏មានអំណរនៅក្នុងអ្វីដែលព្រះកំពុងធ្វើផងដែរ។

- ដេកលក់ស្រួល (ទំនុកតម្កើង ១២៧:២)
- រំពឹងពិតលើសេចក្ដីពិត (ទំនុកតម្កើង ១:២)
- ទូលសូមព្រះគុណ (ហេព្រើរ ៤:១៦)
- អធិស្ឋានសម្រាប់ក្រុមជំនុំ (ភីលីព ១:៩)
- ត្រៀមខ្លួនជាស្រេចក្នុងការលើកទឹកចិត្តគ្នាទៅវិញទៅមក (ហេព្រើរ ១០:២៤)

## ភ្លៀងក្នុងទីរហោស្ថាន

គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ការជួបជុំគ្នានៃពួកបរិសុទ្ធគឺប្រៀបដូចជាភ្លៀងដំបូងដែលព្រះបានប្រទានមកសម្រាប់ការចម្រើនកម្លាំងដល់រាស្ត្ររបស់ព្រះអង្គ។ គ្រីស្ទបរិស័ទជួបជុំគ្នា ដើម្បីថ្វាយបង្គំមិនមែនដោយសារ*ទំនងជា*អ្វីគ្រប់យ៉ាងសុីគ្នាល្អឥតខ្ចោះនោះទេ ឬថាអ្នកដឹកនាំរបស់យើងរៀបផែនការកម្មវិធីថ្វាយបង្គំបានត្រឹមត្រូវ ឬថាមាន

នរណាម្នាក់ញញឹមដាក់យើងដោយការគោរព ការនិយាយគ្នាតិចតួចរបស់យើងបានដោយរលូន និងការសន្ទនារបស់យើងបានត្រឹមត្រូវស៊ីជម្រៅនោះទេ។

យើងមិនមែនជួបជុំគ្នាថ្វាយបង្គំ ដើម្បីឲ្យបានភាពឡូយឆាយនោះទេ ពីព្រោះយើងមិនឡូយឆាយឡើយ។ យើងមិនមែនជួបជុំគ្នាថ្វាយបង្គំដោយសារមានមនុស្សអាយុស្របាលយើងមកគ្នាច្រើនល្មមឡើយ នោះមិនមែនជាចំណុចដែលយើងជួបជុំគ្នាឡើយ។ យើងមិនជួបជុំគ្នាថ្វាយបង្គំដោយសារយើងមានសុវត្ថិភាពឡើយ ពីព្រោះនៅកន្លែងជាច្រើនជុំវិញពិភពលោកនេះ ពុំមានសុវត្ថិភាពទេ។ យើងមិនជួបជុំគ្នាថ្វាយបង្គំដោយសារងាយស្រួល ឬសុខស្រួលនោះទេ ព្រោះយើងមិនបានដើរតាមព្រះអង្គសង្គ្រោះដែលទ្រង់លីខ្នើយនោះទេ ប៉ុន្តែយើងដើរតាមព្រះអង្គសង្គ្រោះដែលទ្រង់បានលីឈើឆ្កាងវិញ។

ផ្ទុយទៅវិញ យើងជួបជុំគ្នាថ្វាយបង្គំទ្រង់ដោយសារព្រះអង្គបានសង្គ្រោះយើងរួចពីអំពើបាបហើយ។ យើងជួបជុំគ្នាថ្វាយបង្គំ ពីព្រោះព្រះអង្គបានអត់ទោសឲ្យយើងរួចហើយ។ យើងជួបជុំគ្នាថ្វាយបង្គំ ពីព្រោះយើងបានរួមមកតែមួយ។ យើងជួបជុំគ្នាថ្វាយបង្គំ ពីព្រោះព្រះបានរំដោះយើង យើងបានកើត

ជាថ្មី ហើយព្រះអង្គក៏បានបង្គាប់យើងឲ្យនាំដំណឹងល្អនេះប្រកាសទៅដល់ចុងបំផុតនៃផែនដីផងដែរ។ យើងជួបជុំគ្នាថ្វាយបង្គំ ពីព្រោះព្រះអង្គដែលយើងកំពុងថ្វាយបង្គំនេះហើយ ទ្រង់បានបង្កើតការជួបជុំថ្វាយបង្គំរបស់យើងជារបៀបដ៏សំខាន់មួយដែលទ្រង់អាចចម្រើនភាពពេញវ័យខាងឯវិញ្ញាណរបស់យើង បង្ហាត់បង្រៀនយើង ព្រមទាំងកម្សាន្តចិត្តយើងផងដែរ។ ការនេះមិនមែនគ្រាន់តែនៅពេលដែលបទចម្រៀង ឬសេចក្ដីអធិស្ឋាន ឬសេចក្ដីអធិប្បាយប៉ះពាល់ព្រលឹងរបស់យើងចំកន្លែងដែលយើងចង់ឲ្យប៉ះពាល់នោះទេ។ យើងជួបជុំគ្នាដោយសារព្រះជាម្ចាស់បានស្អាងរាស្ត្ររបស់ព្រះអង្គតាមរយៈគ្រប់ពេលដែលយើងជួបជុំគ្នា គ្រប់ទីកន្លែង ដោយមិនមានការអាក់ខានមិនថា យើងមានអារម្មណ៍បែបណានោះទេ។ ដូចជាភ្លៀងធ្លាក់នៅទីវាលដែរ នោះរបៀបជួបជុំរបស់យើងក៏មានដំណើរការដូចគ្នាដែរ។

## បទពិសោធន៍ផ្ទាល់ខ្លួន

ខ្ញុំធ្លាប់មានបទពិសោធន៍ពីការឈឺចាប់រ៉ាំរ៉ៃ ភាពតានតឹងផ្នែកហិរញ្ញវត្ថុ ភាពមមាញឹកនៃកាលវិភាគសិក្សា ការលំបាកជាមួយភាពជាឪពុកម្ដាយ រាង

កាយមានភាពនឿយហត់ បន្ទុកនៃការធ្វើព័ន្ធកិច្ច បញ្ហាផ្នែកទំនាក់ទំនង ការបាក់ទឹកចិត្តរយៈពេលយូរ និងការបែកបាក់ក្នុងក្រុមជំនុំផងដែរ។ ជារឿយៗ ខ្ញុំមានអារម្មណ៍ថា មិនចង់ទៅព្រះវិហារនៅថ្ងៃអាទិត្យដោយចង់សម្រាកនៅផ្ទះ។ ខ្ញុំឈប់នៅកន្លែងចតឡាន ដោយមានចិត្តប្រាថ្នាចង់នៅតែម្នាក់ឯង ខ្ញុំបានដកដង្ហើមធំមួយៗ មុនពេលខ្ញុំដើរសំដៅទៅទ្វាររបស់ព្រះវិហារ ហើយខ្ញុំអង្គុយនៅក្នុងក្រុមជំនុំដោយមានចិត្តព្រួយ និងបន្ទុកលើសលប់ជាខ្លាំង។ ផ្ទុយពីការជួបជុំជាថ្មីជាមួយសហគមន៍នៃសេចក្តីជំនឿ ខ្ញុំចង់ស្នាក់នៅក្នុងពិភពរបស់ខ្ញុំទៅវិញ។ ប៉ុន្តែ រៀងរាល់ពេលដែលខ្ញុំថ្វាយបង្គំ ព្រះនៅតែបន្តកែព្រលឹងវិញ្ញាណរបស់ខ្ញុំជាថ្មីឡើងវិញតាមរយៈបទចម្រៀង និងព្រះបន្ទូល សេចក្តីអធិស្ឋាន និងការសរសើរតម្កើង ភាពស្មោះត្រង់ និងសំណើចការកាច់នំប៉័ង និងពែងនៃពិធីលៀងព្រះអម្ចាស់ ព្រមទាំងទំនួលខុសត្រូវយ៉ាងមុតមាំដែលខ្ញុំមានក្នុងការមើលថែអ្នកដទៃផ្សេងទៀតដែរ។

ខ្ញុំកត់សម្គាល់ឃើញមានភ្ញៀវម្នាក់មកថ្វាយបង្គំជាមួយពួកយើង ហើយខ្ញុំត្រូវបង្ខំចិត្តទៅទទួលស្វាគមន៍គាត់ដោយមិនបានគិតពីស្ថានភាពរបស់ខ្ញុំឡើយ។ ការច្រៀងសរសើរតម្កើងក៏បានចាប់ផ្តើម

ហើយដោយសារបទចម្រៀងនោះមិនមែនជាបទ ដែលខ្ញុំចូលចិត្ត ខ្ញុំឃើញថា មិត្តរបស់ខ្ញុំម្នាក់បាន ចូលរួមច្រៀងយ៉ាងអស់ពីចិត្ត ហើយខ្ញុំពិតជាអរព្រះ គុណព្រះយ៉ាងខ្លាំងដែលគាត់ទទួលបានការលើកទឹក ចិត្ត។ ខ្ញុំបានស្ដាប់ឮទីបន្ទាល់មួយ ហើយការស្រេក ឃ្លានខាងឯវិញ្ញាណបានបំពេញចិត្តរបស់ខ្ញុំ នៅ ពេលដែលខ្ញុំសញ្ជឹងគិតអំពីកិច្ចការរបស់ព្រះដែល ទ្រង់បានធ្វើនៅក្នុងជីវិតអ្នកដទៃទៀត។ គ្រូគង្វាល របស់ខ្ញុំចាប់ផ្ដើមអធិប្បាយ ទោះបីគាត់មិនមែនជា គ្រូអធិប្បាយពូកែវោហារសាស្ត្រ ក៏គាត់បានស្គាល់ យើង បានអធិស្ឋានឲ្យយើង ហើយគាត់ក៏បានរៀប ចំសេចក្ដីអធិប្បាយនោះសម្រាប់យើងដែរ។ គាត់គឺ ជាអ្នកគង្វាលរបស់យើង ដែលព្រះគ្រីស្ទបានតែង តាំងគាត់ឲ្យមើលថែហ្វូងចៀមរបស់ទ្រង់នៅកន្លែង នេះ និងក្នុងពេលនេះផងដែរ។ ខ្ញុំចាប់ផ្ដើមស្ដាប់ឮ អំពីសេចក្ដីពិត ហើយមានជំនឿ ព្រមទាំងទទួល បានការលើកទឹកចិត្ត និងសេចក្ដីស្រឡាញ់ក្នុងរបៀប មួយដែលខ្ញុំមិនអាចទទួលបានវាដោយការខំប្រឹង ប្រែងដោយខ្លួនឯងផ្ទាល់ឡើយ។

ការរួបរួមក៏បានចាប់ផ្ដើម ហើយខ្ញុំដឹងថា ខ្ញុំ បានរក្សាទុកអំពើបាបរបស់ខ្ញុំដោយខ្លួនឯងជាជាង ដាក់វានៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់។ ខ្ញុំមើល

តាមចន្លោះផ្លូវកៅអី ហើយឃើញមានមនុស្សម្នាក់ដែលមានជម្លោះជាមួយខ្ញុំកាលពីពីរទៅបីឆ្នាំមុន។ ភាពល្វីងជូរចត់បានពុះឡើង។ ភ្លាមៗនោះខ្ញុំមានចិត្តធុញថប់ និងតានតឹងណាស់។ ប៉ុន្តែ វាពិបាកណាស់ក្នុងការច្រៀងបទទំនុកតម្កើងបន្ទាប់ដោយមិនចងចាំពីទំនួលខុសត្រូវរបស់ខ្ញុំក្នុងការប្រែចិត្តសម្រាប់ផ្នែករបស់ខ្ញុំ ហើយអត់ទោសឲ្យបុគ្គលនោះចំពោះផ្នែករបស់គាត់ណាស់។ យើងបានបញ្ចប់ដោយការអធិស្ឋានបិទ ហើយខ្ញុំនៅតែមានភាពហត់នឿយ ប៉ុន្តែក្នុងរបៀបមួយចំនួន ខ្ញុំក៏បានធូរស្បើយឡើងវិញដែរ។ បន្ទាប់ពីការថ្វាយបង្គំចប់ ខ្ញុំមិនដឹងថា ខ្ញុំគួរនិយាយជាមួយអ្នកណានោះទេ ប៉ុន្តែព្រះជាម្ចាស់បានដឹកនាំខ្ញុំ ហើយយើងបានចាប់ដៃគ្នា ក៏ដូចជាឱបបន្ទាប់ពីយើងបាន «ជម្រាបសួរគ្នា» ទៅវិញទៅមកនៅក្នុងការរួបរួមនៃគ្រួសារក្នុងពួកជំនុំរបស់យើង។

ពួកគាត់ទាំងនេះគឺជាគ្នីគ្នារបស់ខ្ញុំ ពីព្រោះពួកគាត់ក៏ជារាស្ត្ររបស់ព្រះអង្គដែរ។ លោក មករា ទើបតែទទួលបានការងារថ្មីមួយ ហើយយើងបានអធិស្ឋានសម្រាប់ការនោះមួយខែមកហើយ។ នាង សុភក្ត្រ នឹងមានការវះកាត់ឆាប់ៗនេះ សូមព្រះបានផ្តល់សេចក្តីមេត្តាករុណាមកលើគាត់ផង។ លោក សីហា ទទួលបានការលើកទឹកចិត្តតាមរយៈសេចក្តី

អធិប្បាយ ព្រមទាំងមានអំណរណាស់ ហើយខ្ញុំក៏ដូចគ្នាដែរ។ នាង សុធី បាននាំមិត្តភក្តិម្នាក់មកព្រះវិហារ ហើយគាត់ចង់មកម្ដងទៀត ដើម្បីបានស្ដាប់អំពីដំណឹងល្អ ដែលជាញឹកញាប់ខ្ញុំតែងតែភ្លេចថា ដំណឹងល្អនោះមានពេញដោយអំណាចព្រះចេស្ដា។

តាមរយៈបទពិសោធន៍ទាំងអស់នេះបានទាញខ្ញុំចេញពីការគិតតែពីខ្លួនឯង ហើយក៏នាំព្រលឹងរបស់ខ្ញុំត្រឡប់មកឯដំណឹងល្អវិញ។ ខ្ញុំនៅតែធ្វើដំណើរនៅលើលោកីយ៍នេះ ប៉ុន្តែចិត្ត និងគំនិតរបស់ខ្ញុំនៅកៀកនឹងស្ថានសួគ៌ ជាកន្លែងដែលខ្ញុំបានអង្គុយ ព្រមទាំងមានសុវត្ថិភាពជាមួយព្រះគ្រីស្ទ (អេភេសូរ ២:៦) ដែលទ្រង់បានប្រគល់ព្រះជន្មរបស់ទ្រង់សម្រាប់ខ្ញុំ ដើម្បីឲ្យខ្ញុំអាចមានចំណែកនៃជីវិតអស់កល្បជានិច្ចជាមួយព្រះអង្គ។ ហើយអំណោយទាននេះមិនមែនតែសម្រាប់ខ្ញុំប៉ុណ្ណោះនោះទេ ប៉ុន្តែសម្រាប់*យើងទាំងអស់គ្នា*។

## ទូលសុំព្រះគុណព្រះ ហើយចេញទៅ

ខ្ញុំដឹងថា លោកអ្នកទំនងជាមិនមានអារម្មណ៍បែបនេះនៅសប្ដាហ៍នេះនោះទេ។ លោកអ្នកទំនងជាមិនទទួលបានអារម្មណ៍បែបនេះមួយរយៈពេល។ មូល

ហេតុដែលលោកអ្នកមិនមានអារម្មណ៍ចង់ទៅព្រះវិហារទំនងជាមានហេតុផលល្អ អាក្រក់ ឬកាន់តែអាក្រក់ជាងនេះទៀត។ ប៉ុន្តែ ក្នុងនាមយើងជាចៀមដែលទទួលបានសេចក្ដីស្រឡាញ់ពីអ្នកគង្វាលដូចគ្នា ខ្ញុំសូមឲ្យលោកអ្នកទុកចិត្តព្រះជាម្ចាស់ ទូលសុំព្រះគុណព្រះអង្គ ហើយចេញទៅ។

ចូរចេញទៅ ពីព្រោះក្រុមជំនុំជួបជុំគ្នារៀងរាល់ថ្ងៃអាទិត្យ ដើម្បីទឹកចាំពីការសុគតរបស់ព្រះយេស៊ូវសម្រាប់អំពើបាបរបស់យើង ហើយការមានព្រះជន្មរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ ដែលនោះគឺជារឿងដ៏ជាក់លាក់ដែលយើងត្រូវនឹកចាំ និងប្រារព្ធដោយមិនគិតពីអ្វីផ្សេងទៀតដែលបានកើតឡើងនៅក្នុងជីវិតរបស់យើងឡើយ។

ចូរចេញទៅ ពីព្រោះលោកអ្នកមានការរវល់ជាមួយការងារយ៉ាងច្រើនពេញមួយសប្ដាហ៍ដូចជានាង ម៉ាថា អញ្ចឹង ហើយដូចជានាង ម៉ារាដែរ លោកអ្នកត្រូវតែអង្គុយនៅទៀបព្រះបាទព្រះយេស៊ូវ ហើយស្ដាប់ព្រះបន្ទូលរបស់ទ្រង់ចុះ (លូកា ១០:៣៨-៤២)។

ចូរចេញទៅ ពីព្រោះចម្រៀងនៃពួកបរិសុទ្ធគឺជាបទភ្លេងនៃព្រះគម្ពីរ ហើយព្រលឹងរបស់លោកអ្នកត្រូវការច្រៀង និងស្ដាប់ឮបទចម្រៀងនោះច្រើន

ជាងអ្វីដែលលោកអ្នកចង់ដឹងទៅទៀត។

ចូរចេញទៅ ពីព្រោះព្រះគម្ពីរដែលលោកអ្នកបានស្តាប់ឮបានប្រាប់អំពីដំណើររឿងដ៏ពិតនៅក្នុងលោកីយ៍នេះ ហើយការជួបជុំគ្នានៃពួកបរិសុទ្ធដែលជាសាសន៍នៃស្ថានសួគ៌នៅលើផែនដីនេះគឺមិនខុសពីវត្តមាននៃការជួបជុំគ្នានៅពេលអនាគតនោះទេ។

ចូរចេញទៅ ពីព្រោះអំណោយទានរបស់ព្រះគ្រីស្ទបានបង្ហូរមកលើជីវិតរបស់លោកអ្នកមិនត្រឡប់ទៅវិញដោយទទេនោះទេ ហើយលោកអ្នកមានតួនាទីក្នុងការប្រើប្រាស់អំណោយទានដែលព្រះបានប្រទានមកនេះជាឧបករណ៍ក្នុងការស្អាងដំណាក់ខាងវិញ្ញាណរបស់ព្រះអង្គ។

ចូរចេញទៅ ពីព្រោះទោះបីជាក្រុមជំនុំរបស់លោកអ្នកមានបញ្ហា ក៏ក្រុមជំនុំរបស់លោកអ្នកមានព្រះអង្គសង្គ្រោះ ព្រះដែលព្យាបាល ព្រះដ៏ជាអ្នកគង្វាល និងព្រះដ៏ជាមិត្តរបស់លោកអ្នកដែរ។

ចូរចេញទៅ ពីព្រោះមិនថានៅទីនេះជាមួយលោកអ្នក ឬនៅកន្លែងផ្សេងឆ្ងាយទៀត នោះមានបងប្អូនប្រុសស្រីកំពុងមានការឈឺចាប់ ឬស្រេកឃ្លាន ឬមានការបៀតបៀន ឬជាប់គុកក្តី ហើយប្រសិនបើតាមរយៈការលំបាកទាំងនោះក្រុមគ្រួសារក្នុងក្រុមជំនុំរបស់លោកអ្នកនៅតែថ្វាយបង្គំបាន នោះលោកអ្នក

ក៏អាចថ្វាយបង្គំបានដែរ។

ចូរចេញទៅ ពីព្រោះលោកីយ៍នេះបានទាក់ទាញអារម្មណ៍របស់លោកអ្នកពេញមួយសប្ដាហ៍ ប៉ុន្តែអ្វីដែលលោកអ្នកត្រូវការឃើញ ស្ដាប់ឮ ភ្លក់ នឹងប៉ះនោះគឺជាទឹកនៃពិធីបុណ្យជ្រមុជទឹក និងរូបកាយ ព្រមទាំងព្រះលោហិតរបស់ព្រះគ្រីស្ទ។

ចូរចេញទៅ ពីព្រោះការសម្រាកចុងក្រោយដែលលោកអ្នកត្រូវការ គឺមិនមែនគ្រាន់តែការគេង ឬការចេញផុតពីទីក្រុងប៉ុណ្ណោះទេ ប៉ុន្តែជាការស្វែងរកសេចក្ដីសន្យានៅក្នុងដំណឹងល្អឡើងវិញដែលថា នៅក្នុងព្រះគ្រីស្ទ ទ្រង់បានអត់ទោសឲ្យលោកអ្នក លោកអ្នកបានកើតជាថ្មី ព្រមទាំងមានសេរីភាពផងដែរ។

ចូរចេញទៅ ពីព្រោះថ្មដែលបានបាំងលោកអ្នកនៅក្នុងរូងភ្នំនៃកំហឹង ឬភាពល្វីងជូរចត់ ឬភាពអស់សង្ឃឹម ឬមន្ទិលសង្ស័យ ឬភាពឯកោ ឬការភ័យខ្លាចនោះព្រះអាចប្រមៀលចេញត្រឹមតែមួយយប់ប៉ុណ្ណោះ ហើយនៅពេលដែលព្រះអង្គធ្វើការនោះនោះគ្មានទាហានរ៉ូម៉ាំងណាម្នាក់ ឬសម្ដេចសង្ឃនៃសាសន៍យូដាណាមួយអាចបញ្ឈប់ទ្រង់បានឡើយ។

ចូរចេញទៅ ពីព្រោះសារនៃដំណឹងល្អនេះគឺមិនមែនគ្រាន់តែថា *លោកអ្នក*បានផ្សះផ្សាជាមួយ

ព្រះជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែ*យើង*ក៏បានផ្សះផ្សាជាមួយគ្នាទៅវិញទៅមកផងដែរ។

ចូរចេញទៅ មិនមែនដោយសារការល្បួងលរបស់លោកអ្នកមិនពិតប្រាកដនោះទេ ប៉ុន្តែដោយសារតុនៃនំប៉័ង និងស្រាទំពាំងបាយជូរគឺជាការតំណាងឲ្យការឆ្កាងនៃអំពើបាបដ៏អាក្រក់បំផុតដែលលោកអ្នកធ្លាប់បានប្រព្រឹត្ដិ ហើយក៏ជាការពិតដ៏អាក្រក់បំផុតដែលលោកអ្នកមិនធ្លាប់ឆ្លងកាត់ផងដែរ។

ចូរចេញទៅ ហើយក្នុងដំណើរចេញទៅនោះ ចូររីកលូតលាស់ឡើង។ ចូរចេញទៅ ហើយក្នុងដំណើរចេញទៅនោះ ចូរបម្រើចុះ។ ចូរចេញទៅ ហើយក្នុងដំណើរចេញទៅនោះ សូមឲ្យព្រះរើសបំណែកនៃដួងចិត្តរបស់លោកអ្នក ហើយផ្គុំគ្នាប្រៀបដូចជាផ្នែកនៃផ្ទាំងគំនូរមួយដែលអាចចេញជារូបរាងពេញលេញបានគឺនៅពេលដែលពួកបរិសុទ្ធនៅតែប្ដេជ្ញាចិត្តចំពោះព្រះរាជកិច្ចដែលទ្រង់មានក្នុងការផ្លាស់ប្រែយើងជារៀងរាល់ថ្ងៃ ពោលគឺនៅពេលដែលយើងនិយាយសេចក្ដីពិតដល់គ្នាទៅវិញទៅមកដោយសេចក្ដីស្រឡាញ់ (អេភេសូរ ៤:១៥-១៦)។

ពេលវេលាដ៏សំខាន់បំផុតដែលយើងត្រូវទៅព្រះវិហារ គឺជាពេលដែលយើងមិនមានអារម្មណ៍

ចង់ទៅព្រះវិហារ។ ដូច្នេះ បងប្អូនប្រុសស្រីរួមសេចក្តីជំនឿអើយ *សូមទៅព្រះវិហារ*។

# កំណត់ចំណាំផ្សេងៗ

១. ផ្នែកខ្លះនៃកូនសៀវភៅនេះបានដកស្រង់ចេញពីសៀវភៅរបស់លោក David “Gunner” Gundersen, “The Most Important Time to Go to Church,” *The Gospel Coalition* (blog), ថ្ងៃទី១ មីនា ឆ្នាំ២០១៨, https://www.thegospelcoalition.org/article/most-important-time-to-go-to-church/.

២. កថាខណ្ឌនេះ និងកថាខណ្ឌមុនបានកែសម្រួលចេញពីការបង្ហោះមួយដែលមានចំណងជើងថា “Growing Up: Six Basic Steps toward Maturity,” on my personal blog (DavidAGundersen.com), ថ្ងៃទី១ ឧសភា ឆ្នាំ២០១៧។

# លិបិក្រមតាមព្រះគម្ពីរ

## សញ្ញាចាស់


*លោកុប្បត្តិ*
២៥:២៣...........៥០

*និក្ខមនំ*
១៣:២១-២២......៣៨

*ជនគណនា*
១២................៥០

*២សាំយូអែល*
១១................៦២

*១ពង្សាវតារក្សត្រ*
១៩:៩-១៨.........៤៨

*ទំនុកតម្កើង*
១:២...............៥៥, ៦៨
៤២:៥.............១៦
៥៦:៨..............៤៥
១១៩:១០៥.........២៦
១២៧:២...........៦៨
១៣៣:១...........១៦

*សុភាសិត*
៣:៥-៦............២៦, ៥៦
១១:១៤............៥៥
១៤:១២............១២
១៤:១៥............៥៣
១៧:១៣............៥៥
១៨:១..............២៧
១៨:១៧............៥៥
២០:៥.............១៣, ២៨
២៦:១៧...........៥៦
២៧:៦.............៥៤
២៧:១០...........៤១
២៧:១៥...........៥៣

*សាស្ដា*
៤:៩-១០...........២៧
៧:២០.............៦២

*អេសេគាល*
៣៤:១-២៤........២៩

# សញ្ញាថ្មី


**ម៉ាថាយ**

៥:៩ ...............៥១
៦:១២ .............៦៥
៧:៣–៥ ...........៥៥
៨:៣...............៤១
១១:២៨............៤៥
២៣:២៣–២៤ .....៤៩
២៦:៤១............១៥
២៦:៦៩–៧៥.......៦៣
២៨:១៨–២០.......២០

**ម៉ាកុស**

៤:៣–៨............៣៩
៩:៣៤ .............៥១
១០:៣៧ ...........៦២

**លូកា**

១០:៣៨–៤២ ......៧៥
១៨:១៣ ...........៤៧

**យ៉ូហាន**

១:១២ .............៤១
១:១៣–១៤ ........៤១
១៣:១–១៥ ........៤៨
១៣:៣៤...........៥៨

**កិច្ចការ**

២:៤៤ .............៧
១៥:៣៩ ...........៥១
១៧:១១............៥៣
២០:២៨–៣០ ......៥៣
២០:២៨...........២៩
២០:៣៥ ...........៥៨

**រ៉ូម**

៥:៥ ...............៥៨
៨:៣២.............៥៨
១២:៣–៨..........៦០
១២:៤ .............៦១
១២:១២...........៥៥
១៤:១–១៥ ........៤៩

**១កូរិនថូស**

១១:២៣–២៦ ......៣៦
១២:១២–២៦.......៦១
១២:១២–២៧ ......៣១
១៣:៤.............៥៦
១៣:៧.............៥៦

**២កូរិនថូស**

៥:២១ .............៤៦
១៣:១០ ...........៤៨

**កាឡាទី**

១:៨ ...............៥៤
២:១១–២១ ........៥៤
២:១១–១៤.........៦៣
៦:៩–១០...........៣៨

**អេភេសូរ**
២:៦ ............... ៧៤
២:២១-២២ ........ ៣១
៤:១៤............... ២៧
៤:១៥-១៦ ......... ៣៩, ៦០, ៧៨
៤:៣១-៣២ ....... ៦៥

**ភីលីព**
១:៦ ............... ៦៤
១:៩ ............... ៦៨
២:២ ............... ៥១
៣:១៥............. ៥៣
៤:២ ............... ៥១
៤:២-៣ ........... ៥១

**កូឡូស**
៣:១២-១៤ ........ ៥២

**១ថែស្សាឡូនីច**
២:១៧ ............. ៤១
៥:១៤............... ៥៦, ៦៣

**១ធីម៉ូថេ**
២:៨-១៥ .......... ៥៤
៣:១៥............. ៣១

**២ធីម៉ូថេ**
២:២៥ ............. ៥៦
៣:១៦-១៧ ........ ២៦

**ទីតុស**
១:១០-១៦ ......... ២៩

**ហេព្រើរ**
៣:១៣ ............ ២៧
៤:១២ ............ ១៤
៤:១៦.............. ៦៨
៥:១៤............... ៥៤
៨:១-១០........... ៣៤
៨:១០-១១ ......... ១៣
១០:២៤........... ៦៨
១០:២៤-២៥....... ៣១, ៥៩
១២:១-២ .......... ៣៨
១៣:៧............. ២៩
១៣:១៧ ........... ២៩

**យ៉ាកុប**
១:៥ ............... ២៥, ៥៥
១:២២-២៥ ........ ៣៩
២:១-៧............ ៥៤
៥:៩ ............... ៤៩

**១ពេត្រុស**
២:៥ ............... ៣១

៥:១-៥ . . . . . . . . . . . . .២៩
៥:៧ . . . . . . . . . . . . . . . .៤៥

***២យ៉ូហាន***
១:១២ . . . . . . . . . . . . . .៤១

***៣យ៉ូហាន***
១:១៣-១៤ . . . . . . . . .៤១

IX 9Marks

Building Healthy Churches
ការកសាងក្រុមជំនុំដែលមានសុខភាពល្អ

IS YOUR CHURCH HEALTHY?
តើពួកជំនុំរបស់អ្នកមានសុខភាពល្អដែរឬទេ?
ព័ន្ធកិច្ច 9Marks គឺដើម្បីជួយអ្នកដឹកនាំក្រុមជំនុំឲ្យមានចក្ខុវិស័យព្រះគម្ពីរ និងធនធានជាក់ស្តែងសម្រាប់បង្ហាញសិរីល្អរបស់ព្រះដល់ប្រជាជាតិនានា តាមរយៈក្រុមជំនុំដែលមានសុខភាពល្អ។
ដើម្បីបំពេញការនោះ យើងចង់ឃើញក្រុមជំនុំដែលមានសុខភាពល្អដោយមានលក្ខណៈ ៩ យ៉ាងខាងក្រោមនេះ៖
១. សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ
២. គោលលទ្ធិដែលផ្តោតលើដំណឹងល្អ
៣. ការយល់ដឹងដែលបានផ្លាស់ប្រែចិត្តយ៉ាងពិតប្រាកដ និងប្រកាសដំណឹងល្អតាមព្រះគម្ពីរ
៤. ការយល់ដឹងដ៏ត្រឹមត្រូវពីសមាជិកភាពនៃពួកជំនុំតាមព្រះគម្ពីរ
៥. ការយល់ដឹងពីការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ
៦. ការយល់ដឹងពីការបង្កើតសិស្ស និងការលូតលាស់តាមព្រះគម្ពីរ
៧. ការយល់ដឹងពីការដឹកនាំពួកជំនុំតាមព្រះគម្ពីរ
៨. ការយល់ដឹងពីការអធិស្ឋានតាមព្រះគម្ពីរ
៩. ការយល់ដឹងពីការធ្វើបេសកកម្ម
នៅ 9Marks យើងបានសរសេរអត្ថបទផ្សេងៗ សៀវភៅជាច្រើន ការពិនិត្យសៀវភៅឡើងវិញ និងទស្សនាវដ្តីតាមប្រព័ន្ធអ៊ីនធឺណិត។ ពួកយើងក៏បានរៀបចំសន្និសីទ បានថតទុកការសម្ភាសន៍ និងផលិតធនធានផ្សេងៗទៀត ដើម្បីជួយទ្រទ្រង់ក្រុមជំនុំ និងបង្ហាញពីសិរីល្អរបស់ព្រះ។
សូមចូលទៅកាន់គេហទំព័ររបស់យើង ដើម្បីស្វែងរកមាតិកាជាង ៦០+ ភាសា ហើយចុះឈ្មោះ ដើម្បីទទួលបានទស្សនាវដ្តីតាមប្រព័ន្ធអ៊ីនធឺណិតរបស់យើងដោយឥតគិតថ្លៃ។ សូមមើលបញ្ជីឈ្មោះពេញលេញនៃគេហទំព័រជាភាសាផ្សេងៗទៀតរបស់យើង នៅតំណខាងក្រោមនេះ៖
9marks.org/international

IX 9Marks | Church Questions













crossway.org